**PRIMERICA**
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554
- Life Insurance — ធានារ៉ាប់រងជីវិត
- Car Insurance — ធានារ៉ាប់រងរថយន្ត
- Refinance Your Debts — រៀបចំសងប្រាក់ជំពាក់ឡើងវិញ
- Investments — វិនិយោគទុន
- Office or Home Appointment. ជួបនៅការិយាល័យយើង ឬនៅផ្ទះលោកអ្នកក៏បាន

We also provide translation and interpretation services.
E-mail: 8665823172@primerica.gosolo.com
Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034

# ខ្មែរប៉ុស្តិ៍
# The Khmer Post

**ហាងមាសរស្មី**
SUNSHINE JEWELRY INC
- Fine Jewelry
- Certified Diamonds & Custom Design

មានលក់គ្រឿង អលង្ការ យ៉ាងប្រណិតបំផុត ចេញសញ្ញាបត្រលើពេជ្រអាច ផ្លាក់ ឬ ថ្លៃ មាស ប្រាក់ ពេជ្រ ជូនតាមបំណង ។
យើងមានបទពិសោធន៍ ១៥ឆ្នាំ ហើយមានកេរ្តិ៍ឈ្មោះល្អក្នុងការបំរើសេវាអលង្ការនេះ
702 Washington Avenue, Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com

CAMBODIAN-AMERICAN BIWEEKLY NEWSPAPER
VOLUME 02 ISSUE27 December 19st 2008 - January 09th 2009 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM

## ខ្មែរនៅកាណាដាយកអំណោយទៅចែកជូនកងទ័ពនៅប្រាសាទព្រះវិហារ




ព្រះវិហារ, ខ្មែរប៉ុស្តិ៍ : មាជ សុវណ្ណារ៉ា,

•••ចាប់តាំងពីកងទ័ពសៀមធ្វើការឈ្លានពាននៅតំបន់ប្រាសាទព្រះវិហារ និងភូមិសាស្ត្រខេត្តឧត្តរមានជ័យ រហូតមកដល់ពេលនេះ មានរយៈពេលជាង4ខែហើយ ។ ចំណែកឯប្រជាពល រដ្ឋខ្មែរគ្រប់ទិសទី ដែលមានការឈឺឆ្អាលនឹងរឿងប្រទេសជាតិមាតុភូមិ បានធ្វើការទាមទារគ្រប់រូបភាព

(តនៅទំព័រទី១១)

## ខ្មែរ_អាមេរិកាំងជាង២៥០នាក់ បានចូលរួមដង្ហែរធម្មយាត្រាសន្តិភាព

ដោយ : អ៊ុម លឿម

❖❖❖ស្របពេលដែលពិភពលោកទាំងមូលមានការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិខួបទី៦០ សហគមន៍ព្រះសង្ឃខ្មែរ សហរដ្ឋអាមេរិក ក៏បានប្រារព្ធធ្វើធម្មយាត្រាសន្តិភាពមួយឆ្ពោះទៅកាន់ទីស្នាក់ការអង្គការសហប្រជាជាតិ នៅឯបូរីញូវយ៉ក នៅក្នុងគោលបំណងនាំញត្តិជូនមន្ត្រីអង្គការសហប្រជាជាតិ ដើម្បីជំរុញឱ្យប្រទេសថៃគោរពនូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ និងកិច្ចព្រមព្រៀងនាឆ្នាំ១៩០៧ រវាងកម្ពុជា-សៀម

(តនៅទំព័រទី១១)



ពិសហការី ខ្មែរប៉ុស្តិ៍
...ជូនចំពោះមិត្តអ្នកអានទាំងអស់
...ជូនចំពោះមិត្តអ្នកគាំទ្រទាំងអស់

*Happy Holidays!*

នាឱកាសរដូវបុណ្យទានច្រើនឥតគណនា នៅចុងឆ្នាំ ២០០៨ នេះ អារម្មណ៍របស់យើងបែរជាទឹកដល់អំណរគុណ អ្នកដែលបានចូលរួមផ្តល់ភាពរីកចំរើនឱ្យអាចកើតឡើងបាន គឺនៅលើឧត្តមគតិនេះហើយ ដែលយើងសូមគ្រាន់តែឧទ្ទិសយ៉ាងសាមញ្ញ និងដោយមេត្រីភាពថា :

អំណរគុណដល់លោកអ្នកទាំងអស់ នាឱកាសបុណ្យទាននេះ ហើយ និងសូមជូនពរឱ្យបានសប្បាយរីករាយ

ក្នុងឆ្នាំថ្មី 2009

*During this Holiday Season, the Khmer Post team is thoughtfully of our advertisers & readers and would like to extend our specialthanks to your support throughout the year.*

*Warmest wishes to you and your love ones*

## ទិវាប្រារព្ធបុណ្យ Christmas ឬបុណ្យខួបកំណើតព្រះអង្គម្ចាស់យេស៊ូវគ្រីស្ទ




តារ៉ាចម្រៀងខ្មែរក្មេងពីររូបសម្រាប់បុណ្យគ្រីស្ទម៉ាស់ នៅវិហារក្រុមជំនុំខ្មែរ បាប់ទិស ហ្វីឡាដែលហ្វីយ៉ា ។

. កុមារី ម៉ុកម៉ែន ម៉ារី អាយុ ៤ឆ្នាំ

. កុមារី ផៀង សុជាតា អាយុ ១០ឆ្នាំ ។

(បើចង់ឱ្យបានសម្លេងច្រៀងរបស់កុមារីទាំងពីររូបនេះ **សូមសរសេរមកលោក ម៉ម យិន នៅខ្មែរប៉ុស្តិ៍** ) ។

❖❖❖ពាក្យថាបុណ្យ Christmas ឬ Noel (ប្រែជាពាក្យខ្មែរថា : បុណ្យខួបរំឭកកំណើតព្រះអង្គ "យេស៊ូវគ្រីស្ទ" ។

បុណ្យរបស់គ្រីស្ទសាសនា ដែលជាសាសនាដ៏ធំមួយ មានគ្រីស្ទបរិស័ទជឿប្រមាណជាង ១០០០លាននាក់ នៅលើពិភពលោកទាំងមូល ។

ជារៀងរាល់ឆ្នាំ តែកាលណាចប់រដូវបុណ្យអរព្រះគុណ គ្រីស្ទបរិស័ទ គេនាំគ្នាចាប់ផ្តើមរៀបចំធ្វើបុណ្យខួបរំឭកថ្ងៃកំណើតព្រះអង្គយេស៊ូវគ្រីស្ទនេះ ប្រមាណជិតមួយខែមុនថ្ងៃកំណើត មានដូចជាការតុបតែងដាក់លំអរភ្លើងពណ៌ចំរុះនៅតាមគេហដ្ឋាន តាមដើមឈើមុខផ្ទះ

(តនៅទំព័រទី០៨)

**ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ_អង្គរ**
Angkor International Travel Agency
World Wide Travel & Tour Services
Cambodia – Vietnam – Laos – Thailand
(Since 1991)

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO

Cambodia: Victory Travel
No. 96 Eo Street. 148, Phsar Kandal
Phnom Penh, Cambodia
Tel: 011-892329
Manager SIN PO
CHENDA: 023-221069

Serving all Major air lines :
. SINGAPOR
. EVA AIR
. KOREAN AIRLINES
. MALAYSIA etc...

# កម្ពុជាជំពាក់បំណុលបរទេស ជាង៥ពាន់លានដុល្លារ

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ស៊ុម សុភាឫទ្ធិ**

•••ដោយសារតែការដឹកនាំនិយមបក្សតាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់កំពូល និងខ្វះសមត្ថភាពក្នុងការដឹកនាំ បានរុញច្រានឱ្យសេដ្ឋកិច្ចកម្ពុជាហាក់ដូចជាមិនឃើញមានការបោះជំហានទៅមុខគួរឱ្យកត់សំគាល់សោះ ។





ទន្ទឹមនឹងនេះ អំពើពុករលួយដែលមានលក្ខណៈជាប្រព័ន្ធ បានធ្វើឱ្យមន្ត្រីរាជការតូចតាចមានប្រាក់ខែតិចតួចមិនអាចចាយវាយគ្រប់គ្រាន់ ហើយត្រូវបង្ខំចិត្តបោះបង់ សេចក្តីថ្លៃថ្នូរចោល គឺធ្វើយ៉ាងម៉េចឱ្យតែបានលុយសំរាប់ទ្រទ្រង់ជីវភាពក្រុមគ្រួសារប៉ុណ្ណោះ ។

លើសពីនេះទៀត អង្គការតម្លាភាពរបស់ប្រទេសអាល្លឺម៉ង់បានរកឃើញអំពើពុករលួយយ៉ាងធ្ងន់ធ្ងរ ដែលគ្រាន់តែរយៈពេលមួយថ្ងៃសោះរដ្ឋបាត់បង់លុយអស់ជាង1លានដុល្លារអាមេរិក ហើយរហូតមកដល់ពេលនេះរដ្ឋាភិបាល ហ៊ុន សែន នៅតែពុំព្រមធ្វើច្បាប់ប្រឆាំងអំពើពុករលួយទៀត ទោះបីជាមានការជំរុញពីគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិលក៏ដោយ ។

បើតាមអ្នកនយោបាយម្នាក់ដែលស្និទ្ធនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបង្ហើបឱ្យ ដឹងថា សព្វថ្ងៃនេះរដ្ឋាភិបាលកម្ពុជាជំពាក់បំណុលបរទេសជាង2000លានដុល្លារ ដែលមានប្រទេសរុស្ស៊ី ចិន និងសហរដ្ឋអាមេរិក ។ ក្រៅពីប្រទេសមហាអំណាចរដ្ឋាភិបាល ហ៊ុន សែន មានជំពាក់លុយអង្គការអន្តរជាតិធំៗ មួយចំនួនទៀតផ្នែកឥណទាន ដែលយកមកចាយវាយមិនចំគោលដៅ ។

ជាមួយនឹងការលើកឡើងខាងលើនេះ លោក ជាម យៀប សមាជិកសភាជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា បានឱ្យដឹងថា សព្វថ្ងៃកម្ពុជាជំពាក់សហរដ្ឋអាមេរិកជាង300លានដុល្លារ អតីតសហភាពសូវៀត1500លានដុល្លារ និងចិន 500លានដុល្លារ ។ ម្ចាស់បំណុលទាំងនេះបានរំលឹកពីបំណុលរបស់ខ្លួន ។

ចំណែកលោក អូន ព័ន្ធមុនីរ័ត្ន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានបញ្ជាក់ថា ក្រៅពីប្រទេសមហាអំណាច កម្ពុជានៅជំពាក់បំណុលធនាគារពិភពលោកចំនួន ៨00លានដុល្លារ ប្រទេសគុយវ៉ែតនិងកូតា ប្រមាណ700លានដុល្លារទៀត ។ ទាក់ទិនទៅនឹងការជំពាក់បំណុលបរទេសរ៉ៃណូ.កនេះ គណបក្សប្រឆាំងបានធ្វើការរិះគន់ចំៗចំពោះរដ្ឋាភិបាល ហ៊ុន សែន ថា ប្រាក់បំណុលទាំងនេះ រដ្ឋាភិបាលយកទៅប្រើប្រាស់មិនចំគោលដៅ (តទៅទំព័រទី១៤)


# ការិយាល័យច្បាប់របស់ ជេហ្វ្រី អិន ខែល



Law Offices of
**Jeffrey N. Kale**
Attorney at Law



**ពិគ្រោះករណីច្បាប់ដោយមិនគិតកំរៃ យើងបានបំរើសេវាច្បាប់ជូនដល់សហគមន៍ខ្មែរជាង ២០ ឆ្នាំហើយ .**
**ការិយាល័យ"ច្បាប់ទូទៅ" ដែលមានជំនាញផ្លូវច្បាប់ដូចតទៅ :**

- គ្រោះថ្នាក់រថយន្ត
- បើកបរក្រោមឥទ្ធិពលញៀន ឬពុល
- មានរបួសនៅកន្លែងធ្វើការ
- ទិញលក់អចលនវត្ថុ
- ច្បាប់បើកក្រុមហ៊ុន
- ច្បាប់ឧក្រិដ្ឋកម្ម
- គ្រោះថ្នាក់ដោយរអិល ឬដួល
- រំលោភច្បាប់លើផ្លូវចរាចរ
- ការទារឱ្យសងប្រាក់ជំពាក់ ។ល។

**New Jersey : 856-216-7171**
**1236 Brace Road, Suite K, Cherry Hill, NJ 08034**
**Pennsylvania/Philadelphia: 215-564-6900**
**1700 Sansom St., 3rd Floor, Street, Philadelphia, PA 19103**

**FREE CONSULTATIONS**
Providing legal services to the Cambodian community for 20 years
General Law Office specializing in the following areas of law:

Car Accidents
DUI/DWI
Workplace Injury
Real Estate
Corporate Law
Criminal Law
Slip & Fall Accidents
Traffic Violations
Collections

**សេវាច្បាប់ប្រកបដោយវិជ្ជាជីវៈ នឹងតម្លៃគួរសម អាចមានអ្នកបកប្រែជូនបាន**





# ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300





សូមអញ្ជើញមកមជ្ឈមណ្ឌលធ្វើធ្មេញ"អាដាប"យើងធ្វើចុនពីដើមដល់ចប់បានយើងមានក្រុមទន្តបណ្ឌិត៤រូប ដែលមានជំនាញគ្រប់ជ្រុងជ្រោយនៃវិជ្ជាធ្វើធ្មេញ ។

**មណ្ឌលធ្មេញឯកទេសខាងការទារលំអរ**

**ឯកទេសខាង**

✓ Crowns,
✓ Braces,
✓ Bridges,
✓ Veneers,
✓ Inlay,
✓ Gold Caps,
✓ Implants,
✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅហ្វីឡាដែលហ្សៀតែមួយ ដែលមានបន្ទប់ពិសោធន៍នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចឃ្លាធ្មេញជំនួសដែលផលិតឡើងតាមគុណភាព ដែលលោកអ្នកចង់បានទាំងអស់សុទ្ធតែដំណើរការណ៍ដោយបច្ចេកទេសវិជ្ជាជាន់ខ្ពស់ ហើយប្រើលំនាំប្រព័ន្ធ OSHA ជាក្បួន។

**ទន្តសាស្ត្រទូទៅ**

-ដកធ្មេញ
-បំពេញធ្មេញប្រហោង
-ព្យាបាលប្រហោងដល់ឫសធ្មេញ
-ផ្ទិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
**-សំអាតធ្មេញឱ្យស្អាតៈ** ដោយធ្វើដោយឡេស៊័រមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
-យើងក៏មានធ្វើការសំអាតដោយ"អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

**បើកមជ្ឈមណ្ឌល**

ថ្ងៃ ច័ន្ទ : 10am-6pm
ថ្ងៃ អង្គារ : 10am-6pm
ថ្ងៃ ពុធ : 10am-7pm.
ថ្ងៃ ព្រហស្បតិ៍ : 10am-6pm
ថ្ងៃ សុក្រ : 10am-6pm.
ថ្ងៃ សៅរ៍ : 10am-7pm

**យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់**

Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

**ចុះថ្លៃ 10% ដល់អ្នកគ្មានប័ណ្ណសុខភាព**

**អាចធ្វើផែនការណ៍ចេញថ្លៃរាល់ខែ**

# Bye Bye ឆ្នាំ ២០០៨ !!!

**ដោយ : លោក ពិន សំខុន**

•••ស្លឹកឈើជ្រុះចាកមែក ខ្យល់ត្រជាក់ធ្លាក់មកដល់ ឆ្នាំ២០០៨ ក៏មកដល់ទីបញ្ចប់ ពាក្យជូនពរព្រោងព្រាតពេញសកលលោក បាននាំនូវសេចក្ដីសង្ឃឹមខ្លះមកវិញ បន្ទាប់ពីការខិតខំយ៉ាងអស់ពីចិត្តអស់រយៈពេលពេញមួយឆ្នាំកន្លងមក។

បារ៉ាក អូបាម៉ា ប្រធានាធិបតីអាមេរិកាំងជាប់ឆ្នោត បានបញ្ចេញគម្រោងគួរឱ្យចាប់ចិត្តថានឹងបង្កើនការងារសម្រាប់២លានថ្មី នៅពីរឆ្នាំខាងមុខ... តែមួយសប្ដាហ៍មុនសោះ សេចក្ដីរាយការណ៍របស់ក្រសួងការងារ បានឱ្យដឹងថាមានពលករជាង ៥០ម៉ឺននាក់ថ្មី ទើបនឹងត្រូវបញ្ចប់ពីការងារចិញ្ចឹមជីវិត ។ សហរដ្ឋអាមេរិកបានប្រឹងប្រែងដោះស្រាយបញ្ហាជាតិគ្រប់ជ្រុងណាស់ដែរ តែលទ្ធផលល្អពុំទាន់ទទួលបាននៅឡើយទេ រដ្ឋបាលជាតិនៅតែបង្ហាញភាពរឹងប៉ឹងដើម្បីទប់ទល់នឹងវិបត្តិសេដ្ឋកិច្ច វិបត្តិសង្គម និងវិបត្តិការពារជាតិ ឥតឈប់ឈរ ។

ឆ្នាំ២០០៨ បានផ្ដល់បទពិសោធន៍ដ៏ជូចត់. អ្នករកស៊ីខិតខំទប់កុំឱ្យរលំពាណិជ្ជកម្មខ្លួន. អ្នកធ្វើការបានលុយចាយមិនគ្រប់. ទំនិញឡើងថ្លៃ. សាំងឡើងថ្លៃបីដងលើសមុន. ម្ចាស់ផ្ទះបាត់បង់គេហដ្ឋានរាប់លាននាក់. ធនាគារ ឬរោងចក្រធំៗជាច្រើន បានត្រូវបញ្ចប់សកម្មភាព អារម្មណ៍អស់សង្ឃឹមនៃពលរដ្ឋអាមេរិកាំង ពុំបានឱ្យពួកគេឈប់រកមធ្យោបាយដោះស្រាយនោះទេ ។ ពួកគេពុំបានរស់នៅជាមួយនឹងប្រាក់ចំណេញនោះទេ គេកំពុងចាយប្រាក់ដែលគេបានសន្សំ និងប្រាក់ជំពាក់... ហើយប្រាក់សន្សំនោះ ទៀតសោត ក៏កំពុងតែខ្សត់ថែមទៀត ។ ទោះជាលទ្ធផលយ៉ាងនេះក៏ដោយក្ដី ក៏គេនៅពុំទាន់ឃើញភាពស្រុតចុះនៅសហរដ្ឋអាមេរិក ដដែល ថែមពីនេះ ទៀតនៅឆ្នាំ២០០៨នេះ នយោបាយអាមេរិក បានបង្ហាញទិសដៅថ្មីជាមួយនឹងមេដឹកនាំថ្មី ដែលពលរដ្ឋយល់ថា មនុស្សថ្មីនោះ អាចកាច់ចង្កូតនាវាឱ្យប្ដូរទិសដៅទៅបាន ហើយទិសដៅថ្មីនោះ គឺសេដ្ឋកិច្ចក្នុងស្រុកជាអទិភាពមុននឹងគិតពីកិត្តិយលនៃសហរដ្ឋអាមេរិក នៅចំពោះមុខពិភពលោក ។

នៅចុងឆ្នាំ២០០៨ នេះ ថ្វីត្បិតតែពុំជឿថាភាពរីកចំរើននឹងអាចមកដល់នា១ឆ្នាំ ឬ២ឆ្នាំខាងមុខនេះក៏ដោយក្ដី ពលរដ្ឋអាមេរិកាំងទាំងខ្មៅទាំងស បានបង្ហាញពីភាពកក់ក្ដៅ និងក្ដីសង្ឃឹមចំពោះគម្រោងថ្មីនេះណាស់ ។ ពួកគេមានចរិយាសណ្ដោសដល់រដ្ឋបាល ដែលគេទើបនឹងបោះបង់ចោល ហើយរំភើបអបអរដល់រដ្ឋបាលនឹងមកដល់ថ្មី ព្រោះគេយល់ថា ទោះជាយ៉ាងណាក៏ដោយ ពួកគេជាពលរដ្ឋម្ចាស់ឆ្នោត ជាអ្នកដែលបានជ្រើសរើសវាសនានយោបាយជាតិដោយខ្លួនឯងដែរ ។ ពលរដ្ឋបានដឹងជាមុនថា តើរដ្ឋាភិ-បាលគេនឹងធ្វើអ្វីខ្លះ នៅឆ្នាំ២០០៣ ? នឹងតមុខទៀត តើជីវភាព និងកម្លាំងអាមេរិកាំងនឹងមកពីណា ? ពួកគេផ្ដល់ជំនឿទៅលើការជ្រើសរើសមេដឹកនាំដ៏ប្រសើរបំផុត នៅក្នុងចំណោមមនុស្សដែលសុទ្ធតែប្រសើរដោយគុណសម្បត្តិ ។

នៅក្នុងសភាពការណ៍ដ៏តឹងតែងបំផុតនាពេលនេះ សហរដ្ឋអាមេរិក បានបន្តជីវិតទៅមុខទៀតជាមួយសេចក្ដីសង្ឃឹមដ៏ខ្ពង់ខ្ពស់បំផុតមួយនាចុងឆ្នាំ២០០៨នេះ ពីព្រោះគេបានជឿដ៏ធំធេងមួយទៅលើមេដឹកនាំថ្មីរបស់គេថា ស្រឡាញ់សហរដ្ឋអាមេរិកពិតប្រាកដ ថាមានភាពសុចរិតទៀងត្រង់ពិតប្រាកដ ថានឹងស្មោះត្រង់ចំពោះម្ចាស់ឆ្នោតគ្មានប្រែ ។

ត្រជាក់ស្ទើររឹងធ្លាមមែន តែបុណ្យគ្រីស្មើស នៅតែសំខាន់ដដែល បុណ្យថ្ងៃដាច់ឆ្នាំក៏នៅតែមានប្រជាប្រិយដូចមុន សេចក្ដីសង្ឃឹមនិងឃើញផ្លែផ្កាខ្លះ នៅរដូវស្លឹកឈើលាស់ឡើងវិញ នាខែមិនា ឬឧសភា ឆ្នាំ២០០៩ តទៅជាប្រាកដ ៕

**ពិន សំខុន**

## សេចក្ដីជូនដំណឹង

លោកអ្នកដែលប្រើប្រាស់ទូរស័ព្ទទាំងអស់ សូមជ្រាបថា : ទូរស័ព្ទដៃលោកអ្នកនឹងត្រូវទទួលការហៅចូលពីអ្នកលក់ទំនិញនានា ជាពាណិជ្ជកម្ម ហើយលោកអ្នកនឹងបង់ថ្លៃចំពោះការហៅចូលនោះថែមទៀតផង ។

ដើម្បីការពារកុំឱ្យមានការហៅចូលទាំងនោះ សូមទូរស័ព្ទទៅទប់ស្កាត់នៅលេខ :

**1-888-382 1222 .**

នេះជាលេខបញ្ជី " **Do Not Call** " ដែលលោកអ្នកទាក់ទងមិនប្រើពេលយូរទេ គេអាចធ្វើការទប់កុំឱ្យមានការហៅចូលរបស់ពាណិជ្ជកម្មចំនួន៥ឆ្នាំ ។ លោកអ្នកអានត្រូវ ហៅទៅលេខខាងលើពីទូរស័ព្ទដៃដែលលោកអ្នកចង់ឱ្យគេទប់ស្កាត់ មិនអាចហៅពីទូរស័ព្ទ ផ្សេងទៀតនោះបានទេ ។

**Website : www.donotcall.gov**




# BALDI FUNERAL HOME
1331 S. Broad St.
Philadelphia, Pa 19147
Cell: 267-934-9888
Tel : 215-389-2414

សូមសួររកលោក សេខ ឬ Thomas

**ឈាបណកិច្ចតាមប្រពៃណី**

ឈាបណដ្ឋានមានផ្ដល់ជូននូវក្ដារមឈូស ទីធ្លាសំរាប់បញ្ចុះ រៀបកំរងផ្កា និងសេវាឈាបណកិច្ចច្រើនប្រភេទ តម្លៃទៅតាមប្រភេទដែលត្រូវការសេវាឈាបណកិច្ចតាមវប្បធម៌ និងតាមសាសនា និងបំពេញជូនជាកិត្តិយស យើងនឹងខំឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញសេចក្ដីត្រូវការ និងបំពេញប្រាថ្នារបស់លោកអ្នក ។

**ពិធីបូជាសព**

"បាល់ឌី" ផ្ដល់ជូននូវពិធីបូជាសពគ្រប់បែបជម្រើសរាប់ទាំងឱ្យភ្លើង ក្ដារមឈូសសំរាប់សពទន្ទឹមនោះមានសេវាពិធីបុណ្យតាមវប្បធម៌ ការតម្កល់អដ្ឋិ-ធាតុជាចុងបញ្ចប់។ មានជួយធ្វើលិខិតក្នុងករណីចង់នាំអដ្ឋិធាតុទៅកាន់ប្រទេសមួយទៀត មានចារឈ្មោះសពនៅលើទំព័រ "ខ្មែរប៉ុស្តិ៍" ជូនផង ។





**(Locates in South Philly, convenience traffic, and free parking)**

**Traditional Funeral**

Funeral Home provides caskets, cemetery space, floral arrangements, and funeral service options in various price ranges. Cultural and Religious funeral service is honored. We put full efforts to meet your needs and fulfill your wishes.

**Cremation**

Baldi offers complete cremation options including a combustible casket for the body, on site performing cultural memorial service, final placement of the cremated remains, paperwork assistance in case that need to transport the cremated remains to another country, and the Khmer Post newspaper notices.

# គណបក្សសិទ្ធិមនុស្សប្រជុំនៅហ្វីឡាដែលហ្វីយ៉ា”


លោក កឹម សុខា ប្រធានគណបក្ស សិទ្ធិមនុស្ស


លោក ឈឹម សុធន់ រស់នៅរដ្ឋញូវយ៉ក


លោក កែវ សម្បត្តិ រស់នៅរដ្ឋម៉ាសាឈូសែត


លោក ទួន យុគជា រស់នៅម៉ុងរ៉េអាល ប្រទេសកាណាដា

**គណបក្សសិទ្ធិមនុស្ស**

❖❖❖គណកម្មាធិការដំបន់ហ្វីឡាដែលហ្វីយ៉ា ដឹកនាំដោយ ញ៉ុយ ចំរើន បានបើកកិច្ចប្រជុំជាកិត្តិយសជូនលោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្សដែលទើបមកដល់ក្នុងដំបន់កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០០៨ នៅស្នាក់ការខាងត្បូងរបស់សមាគមខ្មែរ ។

លោក កឹម សុខា ក្នុងកិច្ចប្រជុំដែលសមាជិកសំខាន់ប្រមាណ៣០នាក់ចូលរួមប្រជុំ បានធ្វើសេចក្ដីរាយការណ៍ពន្យល់ពីស្ថានភាព ដែលលោកនឹងសហការីមានបទពិសោធជាក់ស្ដែងនៅពេលបោះឆ្នោតកាលពីខែកក្កដា ឆ្នាំ២០០៨ មុននេះ។

លោក កឹម សុខា ឥឡូវជាសហមាជិកសភាពេញច្បាប់និងជាអតីតបេក្ខជនតំណាងរាស្ត្របីរូបទៅពីសហរដ្ឋអាមេរិក និងកាណាដា បានចូលរួមពន្យល់ពីស្ថានភាព នៃការបោះឆ្នោតកម្ពុជាជូនអង្គប្រជុំ។

-ការបោះឆ្នោតដែលពោរពេញដោយការគម្រាមនឹងលួចបន្លំ ។

សម្ព័ន្ធភាពគណបក្សសិទ្ធមនុស្ស និងគណបក្ស សម រង្ស៊ី ដែលដួលរលំដោយមានការជ្រៀតជ្រែកពីគណបក្សប្រជាជន។

-លទ្ធផលដែលទោះជាបានតិចជាងក្ដីសង្ឃឹមប៉ាន់ស្មាន តែត្រូវបន្ទយការប្ដេជ្ញាចិត្តថា និងរិះរកវិធីបន្ថយសកម្មភាពឱ្យទាល់តែបានទទួលជ័យជំនះ ខ្មែរប៉ុស្ដិ៍បានជួបសម្ភាសន៍ អតីតបេក្ខជនតំណាងរាស្ត្រីទាំងបីរូបដែលយើងសូមជូនការសម្ដែងយោបល់ដូចតទៅ :

លោក ឈឹម សុធន់ រស់នៅរដ្ឋញូវយ៉ក ទៅឈរឈ្មោះនៅមណ្ឌលខេត្តព្រៃវែង ជាបេក្ខជនតំណាងរាស្ត្រគណបក្សសិទ្ធមនុស្ស លោក បាននិយាយប្រាប់ខ្មែរប៉ុស្ដិ៍ថា :

"ខ្ញុំបានចូលរួមបង្កើតគណបក្សសិទ្ធមនុស្សនេះជាមួយលោក កឹម សុខា នៅឆ្នាំ២០០៧- យើងបាននាំគ្នាជាច្រើនពីសហរដ្ឋអាមេរិកនេះទៅចូលរួមបោះឆ្នោតនៅកម្ពុជា ពីព្រោះយើងយល់ថា ពួកយើងមានសមត្ថភាពគ្រប់គ្រាន់នឹងដឹកនាំជាតិបាន ខ្ញុំបានចូលរួមឆាកនយោបាយបានពេលនេះ ពីព្រោះខ្ញុំពុំដែលបានទទួលឱកាសដូចពេលនេះទេ យើងចង់ចម្លងទស្សនៈលទ្ធិប្រជាធិបតេយ្យពីសហរដ្ឋអាមេរិក ទៅជូនឱ្យកម្ពុជាអាចក្លាយជាប្រទេសមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដបាន។

នៅពេលឃោសនា ក៏ដូចពេលបោះឆ្នោត ខ្លួនខ្ញុំក៏ដូចក្រុមការងារយើង ពេលរដ្ឋខ្មែរបានបង្ហាញការទទួលយើងខ្ញុំយ៉ាងកកក្ដៅជាទីបំផុត ខ្ញុំបានទទួលសំឡេងជាង៥០ម៉ឺន សំឡេងខ្ញុំនៅតែយល់ថា ជាលទ្ធិផលតិចជាងការគ្រាំទ្ររបស់ប្រជាពលរដ្ឋដល់យើងខ្ញុំ ពីព្រោះតែការលួចបន្លំសន្លឹកឆ្នោត...។

...ខ្ញុំនៅចង់ចាំ ហើយសប្បាយក្នុងចិត្តចំពោះភាពរាកទាក់របស់ពលរដ្ឋខ្មែរយើង នៅពេលខ្ញុំទៅជួបដល់ផ្ទះគាត់នៅអមផ្លូវ ហើយផ្ដល់សេចក្ដីកក់ក្ដៅក្នុងភារកិច្ចរបស់យើងចំពោះជាតិណាស់។ ក៏ប៉ុន្តែអ្វីដែលរំខានភាពរីករាយនេះគឺអសន្តិសុខ បារម្ភពីការទាក់ទងគមនាគមន៍ បារម្ភពីសុខភាពគ្រប់ពេល ទាំងសុខភាព និងសុវត្ថិភាពជាកង្វល់របស់យើង ហើយចេះតែឆ្លងគ្រប់ដំណាក់កាលរួចទាំងអស់បានដែរ។

...យើងបានឆ្នោតជាង៥ម៉ឺនសំឡេង នៅតំបន់ព្រៃវែង ដែលថ្នាក់ដឹកនាំគណបក្សប្រជាជនឈរជើងនៅទីនោះ បង្ហាញឱ្យឃើញថា ទោះបីជាមានការគំរាមកំហែង ការលួចបន្លំ ការរំខានដូចជាមានការចូលលួចទីស្នាក់ការក៏ដោយប្រជាពលរដ្ឋមានការពុះពារឧបសគ្គយ៉ាងខ្លាំង

(តទៅទំព័រទី១៩)


NEW GOLDEN PALACE RESTAURANT

801-21 Washington Ave.
Phone: 215-627-2822

Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm

**Authentic Chinese & Vietnamese Cuisine**
**Very Delicious and Nutritious**

-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ

**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)

**ពិសេសដោយម្ចាស់ហាង:** មានចុះតម្លៃ **10%**លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement



Manager Special :
-10% OFF
LUNCH & DINNER
Present This Coupon



**ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)**

Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market)
**(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.
**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**



**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ដាំង ឆារសាច់គោ
- មីកន្ដាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉ុងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

# នាទីចងចាំព្រឹត្តិការណ៍ ស៊ូស្លាប់ខ្លួន កុំឱ្យស្លាប់ជាតិ

**ដោយ : លោក ម៉ម ឃិន**

●●●តើហេតុអ្វីបានជាលោក ប៉ែន សុវណ្ណ ត្រូវបានលោក ហ៊ុន សែន ចាប់ដាក់គុកងងឹតនៅក្រុងហាណូយប្រទេសយួន ដូច្នេះទៅវិញ ?

សំនួរខាងលើនៅ បានលេចចេញមកពីបណ្ដាជនមួយចំនួន ដែលធ្លាប់បានដឹងថា លោក ប៉ែន សុវណ្ណ ជាមនុស្សម្នាក់ បានចូលទៅរៀនសូត្រ និងរួមកិច្ចការងារជាមួយពួកក្រុមខ្មែរ យៀកមិញ តាំងពីនៅវ័យកុមារមកម្លេះ រហូតមកដល់ឆ្នាំ ១៩៥៤ នៅក្រោយពេលសន្និសីទអន្តរជាតិ ស្ដីពីការការពារឯករាជ្យប្រទេសទាំងបី នៅឥណ្ឌូចិន ខ្មែរ លាវ យួន ។

ពេលលោក ប៉ែន សុវណ្ណ បានរស់នៅជាមួយយួនយៀកមិញ ដែលតម្រូវឱ្យដកទ័ពចេញឱ្យអស់ត្រឡប់ទៅកាន់ប្រទេសយួនយៀកមិញវិញ តាមសេចក្ដីសម្រេចនៃសន្និសញ្ញាក្រុងហ្សឺណែវនោះដែរ ។

លុះមកដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃទទួលជោគជ័យដ៏ត្រចះត្រចង់នៃកងទ័ពយួន យៀកមិញ ប្រមាណពីរសែននាក់ ទៅលើក្រុមខ្មែរក្រហម កម្ពុជាប្រជាធិបតេយ្យ ស្រាប់តែបានឃើញវត្តមាននៃលោក ប៉ែន សុវណ្ណ រួមជាមួយលោក ហេង សំរិន លោក ជា ស៊ីម និងលោក ហ៊ុន សែន ផងដែរ នៅក្នុងប្រទេសខ្មែរ ហើយត្រូវបានកងទ័ពយួនតែងតាំងឱ្យធ្វើជាក្រុមដឹកនាំប្រទេសខ្មែរ ជំនួសក្រុមខ្មែរក្រហម កម្ពុជាប្រជាធិបតេយ្យ ។

នៅពេលកងទ័ពយួនបានចូលឈ្លានពានលុកលុយ ហើយបានទទួលជោគជ័យ ហើយក៏បានដូរឈ្មោះថា សាធារណរដ្ឋប្រជាមានិតទៅវិញ។ លោក ប៉ែន សុវណ្ណ ក៏ត្រូវបានកងទ័ពយួន តែងតាំងឱ្យធ្វើជាអគ្គលេខាធិការមជ្ឈឹមបក្សបដិវត្តន៍កម្ពុជា ។

លុះមកដល់ចុងឆ្នាំ១៩៨១ លោក ប៉ែន សុវណ្ណ ត្រូវបានកងទ័ពយួនបញ្ជាឱ្យលោក ហ៊ុន សែន និង សាយប៊ូថង ចាប់បញ្ជូនទៅដាក់គុកងងឹត នៅក្រុងហាណូយ ដោយចោទប្រកាន់ថា លោកធ្វើការប្រឆាំងនឹងវត្តមានរបស់កងទ័ពយួន នៅក្នុងប្រទេសកម្ពុជា និងបានប្រឆាំងនឹងយុទ្ធនាការ **ក៥** របស់យួន ដែលបង្ខំឱ្យលោកធ្វើយុទ្ធនាការកាប់បំផ្លាញព្រៃឈើ ។

លោក ប៉ែន សុវណ្ណ បានមានប្រសាសន៍ថា យុទ្ធនាការយួន មានផែនការក្ដោបប្រទេសខ្មែរ តាមរបៀបយកខេត្តខ្មែរនិមួយៗត្រូវដាក់ក្រោមការត្រួតត្រាពីខេត្តរបស់ប្រទេសយួន មានន័យថា ដើម្បីគ្រប់គ្រងប្រទេសខ្មែរ ឱ្យបានច្បាស់លាស់ យួនយកខេត្តខ្មែរធ្វើជាអាណានិគមរបស់ខេត្តយួន ។

លោក ប៉ែន សុវណ្ណ បានអះអាងប្រាប់អ្នកសារព័ត៌មានសិទ្ធិសេរីភាព ក្នុងពេលដែលគាត់កំពុងដឹកនាំរបបសាធារណរដ្ឋប្រជាមានិតបដិវត្តន៍កម្ពុជា គាត់មានការព្រួយបារម្ភចំពោះឧបាយកលរបស់យួនណាស់ ជាពិសេស នៅពេលដែលយួន បានចាប់រូបលោកដាក់គុកងងឹត ដោយសារមានករណីពីរ ដែលរូបលោកបានស្នើសុំឱ្យយួនគោរពអធិបតេយ្យភាពជាតិរបស់ខ្មែរ ។

- ទី១ : យួនត្រូវតែដកកងទ័ពចាកចេញពីប្រទេសខ្មែរ ប្រសិនបើយួនចាត់ទុកខ្មែរជាមិត្តមុីនឆ្នាំ ហើយជួយខ្មែរដោយស្មោះត្រង់ យួនត្រូវតែគោរពសិទ្ធិស្វយ័ត ក្នុងការគ្រប់គ្រងជាតិខ្មែរដោយខ្លួនឯង ។ ចំណុចនេះ ធ្វើឱ្យយួនយល់ច្បាស់ថា លោក ប៉ែន សុវណ្ណ នៅមានគំនិតជាតិនិយមច្រើន ដោយរាល់ការអនុម័តយុទ្ធសាស្ត្រផ្សេងៗ រូបលោកផ្ទាល់ជាអ្នកជំទាស់ ។

- ទី២ : គឺលោក ប៉ែន សុវណ្ណ មិនព្រមឱ្យយួនអនុវត្តន៍ផែនការយុទ្ធនាការ **ក៥** ដែលនាំឱ្យបងប្អូនប្រជាពលរដ្ឋខ្មែរ និងពលករទាំងប្រុសស្រីមានគ្រោះថ្នាក់ ដោយសារផ្ទៃដីប្រមាណ


លោក ប៉ែន សុវណ្ណ

៣៥% ក្នុងសម័យនោះ ពោរពេញទៅដោយមីនចំការមីន ។

លោក ប៉ែន សុវណ្ណ បានយល់ច្បាស់អំពីផលលំបាកក្នុងការកាប់បំផ្លាញព្រៃឈើ ដែលជាយុទ្ធនាការ **ក៥** របស់យួន នៅក្នុងអត្ថន័យ និងអាថិកំបាំង ដែលលោក ប៉ែន សុវណ្ណ បានបញ្ជាក់ថា: **ក** ទាំង **៥** ពាក្យនេះ មាននិយមន័យដូចខាងក្រោយនេះ :

**ក** ទី១ : កាប់ឆ្ការព្រៃ

**ក** ទី២ : កំទេចព្រៃឈើខ្មែរកុំឱ្យសល់

**ក** ទី៣ : កម្ពុជាកេណ្ឌពលករបើកយុទ្ធនាការបំផ្លាញព្រៃ

**ក** ទី៤ : កេណ្ឌកងទ័ពដើម្បីកាប់ព្រៃឈើ

**ក** ទី៥ : កំចាត់ពូជខ្មែរ តាមរយៈ **ក៥**

នៅពេលដែលលោក ប៉ែន សុវណ្ណ ពុំបានយល់ស្របតាមគោលនយោបាយយួនរបស់នោះហើយ ដែលបានបណ្ដាលឱ្យយួនសង្ស័យគាត់ ហើយយួនក៏បានចោទប្រកាន់ពីបទបង្កសង្គ្រាមរួចក៏ចាប់រូបលោកទៅដាក់គុកងងឹត នៅហាណូយជាង១០ឆ្នាំ ។

នៅក្នុងសម័យលោក ប៉ែន សុវណ្ណ ក៏មានលោក ចាន់ ស៊ី ជាអ្នកប្រឆាំងនឹងយុទ្ធនាការ **ក៥** នេះដែរ រហូតពួកយួនបានចាក់ថ្នាំសម្លាប់បំបិទមាត់ចោលទៅ ។ ទាំងអស់នេះ ជាទង្វើយ៉ាងព្រៃឃោឃៅរបស់យួនមកលើអ្នកជាតិនិយមខ្មែរគ្រប់ៗសម័យកាលទាំងអស់ ។

លោក ប៉ែន សុវណ្ណ បានអះអាងថា ការកាប់បំផ្លាញព្រៃឈើនេះ ជាជំងឺអាក្រក់មួយមកដល់សព្វថ្ងៃនេះ ដែលតម្រូវឱ្យរដ្ឋាភិបាល និងឈ្មួញទុច្ចរិតបន្តបំផ្លាញព្រៃឈើស្ទើរគ្មានសល់ បើទោះបីជាមានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង និងអភិរក្សយ៉ាងណាក៏ដោយ ក៏វិនាសកម្មនេះមានទំហំធំធេងគួរឱ្យព្រួយបារម្ភខ្លាំងណាស់ ។

ក្រោយពីរដ្ឋាភិបាល បានកាប់បំផ្លាញព្រៃឈើ វាបានបង្កឱ្យមានទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងៗជាច្រើន ដែលមានផលប៉ះពាល់ដល់សង្គមជាតិឥឡូវនេះ ។

រដ្ឋាភិបាល និងអ្នកមានទ្រព្យសម្បត្តិ និងពួកឈ្មួញទុច្ចរិត បានបើកយុទ្ធនាការចាក់ដីបំពេញចូលទៅក្នុងបឹងស្ទើរគ្រប់ទីកន្លែង រួមមានបឹងស្នោ បឹងពោងពាយ បឹងប្រយ៉ាប បឹងទំនប់ បឹងត្របែក ។ល។ ដូច្នេះធ្វើឱ្យមានគ្រោះទឹកជំនន់ និងគ្រោះមហន្តរាយកាន់តែខ្លាំងឡើង ។

ព្រៃឈើ ដែលបានបម្រើប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រមួយចំនួន ដូចជា ការស្វែងរកផ្ដៅ វល្លិ ជ័រ ជាដើម ប៉ុន្តែព្រៃឈើ ដែលធ្លាប់ផ្ដល់ប្រយោជន៍ដល់ប្រជាពលរដ្ឋខ្មែរ ត្រូវបានអ្នកមានអំណាច កាប់បំផ្លាញស្ទើរគ្មានសល់ ។

ម្យ៉ាងវិញទៀត លោក ប៉ែន សុវណ្ណ បានបញ្ជាក់ថា ការលប់បឹងជុំវិញទីក្រុង និងតាមខេត្តនានា បានផ្ដល់ផលលំបាកយ៉ាងច្រើនដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ដែលពួកគាត់បានពឹងផ្អែកទាំងស្រុងទៅនឹងបឹង ស្ទឹង អូរ ទាំងនោះ ដើម្បីយកមកទទួលទាន ។

ក្នុងរឿងលោក ប៉ែន សុវណ្ណ បានជាប់គុកងងឹតនៅហាណូយ ស្រុកយួននេះ បានធ្វើឱ្យបណ្ដាជនមានការងឿងឆ្ងល់ ហើយចង់ដឹងពីដំណើររឿងនេះណាស់ដែរ ពីព្រោះតាំងតែពីពេលបានដឹងថា លោក ប៉ែន សុវណ្ណ ត្រូវចាប់ខ្លួន ហើយបញ្ជូនទៅដាក់គុកងងឹតនៅហាណូយនោះ ពុំបានដឹងថា តើលោក ប៉ែន សុវណ្ណ មានទោសជាប់គុកដោយសាររឿងអ្វី ហើយហេតុអ្វីមិនចាប់គុកនៅស្រុកខ្មែរ ?

ដូច្នេះការងឿងឆ្ងល់ទាំងនេះ បានស្ថិតនៅក្នុងការអាថិកំបាំងសម្ងាត់រហូតមក លុះមកដល់ឆ្នាំ១៩៩៣ ទើបយួនបានដោះលែងលោក ប៉ែន សុវណ្ណ ឱ្យវិលត្រឡប់មកស្រុកខ្មែរវិញ ដោយចាត់ទុកជាប្រជាពលរដ្ឋខ្មែរធម្មតាម្នាក់រៀងរហូតមក ។

ដោយសារការចង់ដឹង និងការងឿងឆ្ងល់នេះហើយ ទើបបណ្ដាលឱ្យអ្នកយកព័ត៌មានទៅជួបលោក ប៉ែន សុវណ្ណ ហើយធ្វើបទសម្ភាសន៍សុំឱ្យគាត់ថ្លែងបញ្ជាក់ពីមូលហេតុដែលនាំឱ្យយួនបញ្ជាឱ្យលោក ហ៊ុន សែន និង សាយប៊ុនថង ចូលទៅផ្ទះគាត់ ប្រកាសដកតំណែងទាំងអស់ពីគាត់ ហើយដាក់ខ្នោះ ចងមុខ បញ្ជូនគាត់ទៅដាក់គុកងងឹតនៅហាណូយ ដូចមានសេចក្ដីថ្លែងបញ្ជាក់របស់លោក ប៉ែន សុវណ្ណ ខាងលើនេះស្រាប់ ។

ក្រោយពីបានដឹងមូលហេតុទាំងប៉ុន្មាននោះហើយបានបណ្ដាលឱ្យបណ្ដាជនច្រើនណាស់អស់មានសេចក្ដីងឿងឆ្ងល់ ហើយយល់យ៉ាងប្រាកដថា កងទ័ពយួនយៀកមិញ ដែលជាចៅហ្វាយរបស់លោក ហេង សំរិន លោក ជា ស៊ីម និងលោក ហ៊ុន សែន ប្រាកដជាមានផែនការ ក្នុងការត្រួតត្រាគ្រប់គ្រងប្រទេសខ្មែរ ដោយតាំងខ្លួនជាអាណានិគមថ្មីមួយត្រួតត្រាទៅលើប្រទេសអតីតឥណ្ឌូចិនទាំង៣ ខ្មែរ លាវ យួន ដែលមានយួនជាមេក្លោងសហព័ន្ធឥណ្ឌូចិន ដែលប្រទេសយួនមានផែនការអស់រយៈពេលរាប់រយឆ្នាំមក ហើយនោះ ជាពិតប្រាកដមែន ។

សរុបសេចក្ដីទៅ ការថ្លែងបញ្ជាក់អំពីការចាប់គុកងងឹតនៅហាណូយ និងថ្លែងអំពីអាថិកំបាំងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលកងទ័ពយួនយៀកមិញ បានចូលមកលុកលុយ ហើយបានទួលជ័យជំនះ ថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៧៩ ហើយនិងការអនុវត្តន៍ផែនការ **ក៥** របស់កងទ័ពយួននោះ គឺជាការសំដែងពីទឹកចិត្ត និងឧត្ដមគតិ សតិស្មារតី មនសិការស្នេហាជាតិដ៏ពិតប្រាកដរបស់លោក ប៉ែន សុវណ្ណ ដោយប្រើយុទ្ធវិធីចូលបំរើចោរ **(តនៅទំព័រទី...)**



# ប្រវត្តិនៃវិបត្តិចុងក្រោយនៅប្រទេសថៃ

**. មូលហេតុនៃវិបត្តិ**

•••ប្រទេសថៃបានជួបប្រទះនូវវិបត្តិនយោបាយមួយ កាលពីអំឡុងឆ្នាំ១៩៩៩មក ដោយសារតែមានក្រុមប្រឆាំងរដ្ឋាភិបាលមួយឈ្មោះ ក្រុមសម្ព័ន្ធមិត្តប្រជាជន ដើម្បីលទ្ធិប្រជាធិបតេយ្យបានចោទប្រកាន់រដ្ឋាភិបាលនៃលោកឧត្តមសេនីយ៍ ត្រីតម្រួត ថាក់ស៊ីនថា ជានាយករដ្ឋមន្ត្រីមាននយោបាយដឹកនាំប្រទេសជាតិ ដោយគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន គ្រួសារបក្សពួកនិយមលក់ទឹកដីឱ្យជនបរទេស ធ្វើឱ្យប៉ះពាល់ដល់បូរណភាព អធិបតេយ្យភាពរបស់ប្រទេស និងជនជាតិថៃ ។ រឿងពិសេសម្យ៉ាងទៀត គឺការប្រព្រឹត្តអំពើកេងប្រវ័ញ្ច លួចបន្លំថវិកាជាតិ ។

ទង្វើនៃនាយករដ្ឋមន្ត្រី ថាក់ស៊ីន នេះជាមូលហេតុដ៏ធំធេងមួយ ដែលក្រុមប្រឆាំងត្រូវតែចេញមុខធ្វើការប្រជុំមហាបាតុកម្មមហាជន ដោយសន្តិវិធី អហិង្សា និងក្នុងរបៀបរៀបរយ នៅពាសពេញប្រទេសថៃអស់រយៈពេល១ឆ្នាំ។

**▸ការទម្លាក់នាយករដ្ឋមន្ត្រី ថាក់ស៊ិន**

ដោយមហាបាតុកម្មមហាជនថៃ ក្រោមការដឹកនាំរបស់សម្ព័ន្ធមិត្តប្រជាជន ដើម្បីលទ្ធិប្រជាធិបតេយ្យ មានឈ្មោះលោក បណ្ឌិតសន្ធិ លឹមថងគុន បានធ្វើជាប់ជានិច្ច ដើម្បីតវ៉ាទាមទារឱ្យនាយករដ្ឋមន្ត្រី ថាក់ស៊ិន ចុះចេញពីតំណែង ។

មហាបាតុកម្មបានបញ្ចប់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៦ ដោយកងទ័ពជាតិថៃបានចេញមកធ្វើរដ្ឋប្រហារទម្លាក់នាយករដ្ឋមន្ត្រី ថាក់ស៊ិន ចេញពីតំណែងប្រកបដោយជោគជ័យ និងដោយគ្មានចំណាយគ្រាប់កាំភ្លើង សូម្បីតែមួយគ្រាប់ក៏គ្មានដែរ ។ ភាពស្ងប់ស្ងាត់ និងរបៀបរៀបរយនៅក្នុងប្រទេស បានវិលមករកភាពប្រក្រតីវិញ ក្រោមការដឹកនាំរបស់រដ្ឋាភិបាលបណ្តោះអាសន្នមួយ ដែលមានលោកឧត្តមសេនីយ៍ ស៊ូរយុត ចល់ឡានន់ ជានាយករដ្ឋមន្ត្រីថ្មី ។



លោក ស៊ុមឆៃ វង់សាវ៉ាត់ នាយករដ្ឋមន្ត្រីសៀមទើបធ្លាក់ពីតំណែង



ក្រុមបាតុករប្រឆាំងនឹងរដ្ឋាភិបាលសៀម

សភាធម្មនុញ្ញមួយ ក៏បានបង្កើតឡើងដែរ ដើម្បីតាក់តែងច្បាប់រដ្ឋធម្មនុញ្ញថ្មីមួយទៀត សំរាប់រៀបចំការបោះឆ្នោតសកលជ្រើសរើសតំណាងរាស្ត្រនៃរដ្ឋសភាជាតិទាំងពីរ និងជ្រើសរើសនាយករដ្ឋមន្ត្រីថ្មី ត្រឹមត្រូវពេញលក្ខណៈច្បាប់ ។

សូមរលឹកថា នៅពេលដែលរដ្ឋប្រហារ បានទម្លាក់នាយករដ្ឋមន្ត្រី ថាក់ស៊ីន ទៅគណបក្សលោកឈ្មោះ " ថៃរ័កថៃ " ក៏ត្រូវតុលាការជាន់ខ្ពស់ប្រកាសរំលាយចោលដែរ ហើយមន្ត្រីគណកម្មាធិការប្រតិបត្តិ១១១នាក់ ក៏ត្រូវបាត់បង់សិទ្ធិធ្វើជាបេក្ខជនអស់រយៈពេល៥ឆ្នាំដែរ ។

លោកអតីតនាយករដ្ឋមន្ត្រី ដែលត្រូវនិរទេសទៅនៅប្រទេសក្រៅ បានបញ្ជាឱ្យក្រុមពក្សពួកលោកបង្កើតគណបក្សថ្មីមួយទៀតដាក់ឈ្មោះថា "ផ្លាំងប្រជាជន"(កម្លាំងប្រជាជន)បន្តទៅទៀត ដើម្បីចូលរួមបោះឆ្នោតឆ្នាំ២០០៧ ។

ដោយសារឥទ្ធិពលនៃលុយមហាសាល បានធ្វើឱ្យមានការគាំទ្រយ៉ាងច្រើន ទើបបណ្តាលឱ្យគណបក្សផ្លាំងប្រជាជន មានលោក ស្មាក់ ស៊ុនណារ៉ាវេត បានទទួលជោគជ័យជាថ្មីម្តងទៀត មានន័យថា អំណាចរបស់អតីតនាយករដ្ឋមន្ត្រី ថាក់ស៊ិន បានត្រូវប្រគល់មកឱ្យលោក ស្មាក់ ធ្វើជំនួសជានាយករដ្ឋមន្ត្រីថ្មី ដឹកនាំរដ្ឋាភិបាលនៃប្រទេសថៃនៅចុងឆ្នាំ ២០០៧នោះទៅ ។

(តទៅទំព័រទី២ ១)


# ទៅណាទៀត ?

បន្ទាប់ពីជួបវេជ្ជបណ្ឌិតរួចហើយ

ឱសថស្ថានWASHINGTON AVENUE

នឹងជួយដល់តម្លៃទិញថ្នាំពេទ្យ ជាពិសេសចំពោះ

គ្រួសារ ដែលមានប្រាក់ចំណូលតិចតួច

កុំភ្លេចយក

រង្វាន់ដោយឥតគិតថ្លៃ

៣០ សីហា



កាតាបធ្វើដំណើរ

នៅមានរង្វាន់ពីរទៀត



ដបវីតាមីនមួយ
វីតាមីន D
វីតាមីន C
វីតាមីនសំរាប់ស្ត្រី
វីតាមីនសំរាប់បុរស

ពិសេសសំរាប់អ្នកមានជំងឺទឹកនោមផ្អែម

ប្រដាប់វាស់ស្ករឈាមដោយឥតគិតថ្លៃ




* ស្រួលប្រើ
* លឿន
* ត្រឹមត្រូវ
* ឥតឈឺ

Washington Ave
ឱសថស្ថាន
215-755-5100

* សំរាប់តែគ្រួសារដែលមានប័ណ្ណ

600 Washington ave, Unit 18E Phila, PA - phone: 215-755-5100



# ឱសថស្ថាន ផ្លូវលេខ 8

វេជ្ជបណ្ឌិត អាឡិច លឿង

8th Street Pharmacy
Alex. N. Luong, RPh.

OPEN HOURS:
Mon. – Fri.: 9:00AM – 7:00PM
Sat.: 9:00AM – 5:00PM
Sun.: 9:00AM – 3:00PM

បើចង់បានសេវាថ្នាំពេទ្យឆាប់ សូមអញ្ជើញមករកអ្នកភូមិរបស់អ្នក គឺ ឱសថស្ថាន ផ្លូវលេខ ៨ ( ជ្រុងផ្លូវលេខ៨ និង CHRISTIAN ហ្វីឡា-ខាងត្បូង)

☛យើងទទួលប័ណ្ណមេឌីឃែរ នឹងមេឌីខេត

▸We Do accept Medicare & Medicaid

▸ We Do Offer Alternative Natural Medicines Including:

☛យើងមានផ្តល់ជូននូវឱសថធម្មជាតិ មានដូចជា :



▸ Prostate -7 – ជួយដល់សុខភាព "ប្រស្តេដ" ដល់បុរស
▸ Pure Fresh Royal Jelly – ជួយលើកដំកើងនូវរសជាតិនៃជីវិត
▸ Fe-mon-9 – ជួយដល់ស្ត្រីនៅពេលមានអ័រម៉ូន
▸ Super Cross – ជួយបន្ថយការគាំងបេះដូង,ការលើសឈាម ឬកូឡេស្តេរ៉ូលច្រើន
▸ Gold Medal Swiss Placenta "សុកពពែស្វីស" មេដាយមាស សំរាប់កែសម្ផស្ស

819 S. 8th St.
Philadelphia, Pa 19147
Phone: 215-592-8888
Fax: 215-592-9888

# កម្ពុជាគ្មានព្រំដែនត្រួតស៊ីគ្នានៅចំណុចប្រាសាទព្រះវិហារជាមួយសៀមទេ

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល**

●●●ជម្លោះព្រំដែនកម្ពុជា-សៀមនៅចំណុចប្រាសាទព្រះវិហារ បានក្លាយជាប្រធានបទ ក្តៅគគុក ហើយប្រជាពលរដ្ឋខ្មែរទាំងក្នុង និងក្រៅប្រទេសផ្តោតការចាប់អារម្មណ៍យ៉ាងខ្លាំង ដោយមានការជួយគាំទ្រទាំងផ្នែកផ្លូវកាយចិត្ត និងសំភារៈជាបន្តបន្ទាប់ ។

ជាមួយគ្នានេះដែរ ក៏បានធ្វើឱ្យមតិអន្តរជាតិមួយចំនួនដែលយកតាមផែនទីឯកតោភាគីនោះថា ព្រំដែនជម្លោះនោះមានការត្រួតស៊ីគ្នា 4,6 គីឡូម៉ែត្រ ហើយពួកសៀមបានបន្តការឈ្លានពាននៅតាមចំណុចមួយចំនួនក្នុងទឹកដី ខេត្តព្រះ-វិហារ និងឧត្តរមានជ័យ គ្មានការអៀនខ្មាស ។

ការភ័ន្តច្រឡំនេះ ត្រូវបានក្លឹបអ្នកកាសែតកម្ពុជា រៀបចំសន្និសីទសារព័ត៌មាន កាលពីថ្ងៃទី 18 ខែវិច្ឆិកា កន្លងមក នៅទីក្រុងភ្នំពេញ ដើម្បីពន្យល់ពីបញ្ហានេះឱ្យមតិជាតិ និងអន្តរជាតិបានជ្រាបកាន់តែច្បាស់ ។

ក្នុងឱកាសនោះលោកបណ្ឌិត រស់ ចន្ទ្រា បុត្រ អនុប្រធានរាជបណ្ឌិតសភាកម្ពុជា បានឱ្យដឹងថា ផែនទីតែមួយគត់ដែលទទួលស្គាល់ជាអន្តរ-ជាតិដោយបារាំង និងសៀម ។

ដោយសារតែផែនទីនេះហើយ ទើបខ្មែរអាចធ្វើការតវ៉ាទៅទីក្រុងឡាអេ ហើយឈ្នះក្តីលើសៀមកាលពីថ្ងៃទី15 ខែមិថុនា 1962 ដែលសៀមកាលណោះគ្មានការតវ៉ាអ្វីបន្តិចសោះ ។ ចុះហេតុអ្វី បានជាពេលនេះសៀមបែរជាថា ផែនទីត្រួតស៊ីគ្នានៅចំណុចប្រាសាទព្រះវិហារ



ផែនទីប្រាសាទព្រះវិហារនៅសម័យបារាំង

4,6គីឡូម៉ែត្រទៅវិញ ។

លោក រស់ ចន្ទ្រាបុត្រ បានបន្តថា ភាគីសៀមបានយល់ព្រមដោះស្រាយបញ្ហាព្រំដែនជាមួយនឹងកម្ពុជា តាមអនុស្សរណៈយោគយល់គ្នា MOU កាលពីឆ្នាំ2000 ។ ទោះជាមានបញ្ហានេះក្តី សៀមថា ផែនទីជារឿងមួយដោយឡែក និងបានប្រើប្រាស់ពេលវេលាចរចាអូសបន្លាយបញ្ហាព្រំដែនកាន់តែយូរ រហូតបញ្ជូនទៅដល់រដ្ឋសភាទៀត ។

ចំណែកលោក គិន ភា អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា បានអះអាងថា បើសិនជាសៀមមិនព្រមកែប្រែមហិច្ឆតា និងការឈ្លានពាននោះទេ ការចរចាភាគីទាំងពីរពុំបានទទួលជោគជ័យឡើយ ។ អ្វីដែលមានឥទ្ធិពលលើសៀមនោះ គឺការដោះស្រាយឱ្យមានភាគីច្រើន (តទៅទំព័រទី២០)


ទិដ្ឋភាពប្រាសាទព្រះវិហារ


ការចរចាទ្វេភាគីកម្ពុជា_សៀម នៅសៀមរាប

**Washington Wellness Care** មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"

Medical & Rehab.

ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

**Dr. Scott C. Tran, D.C.** **Dr. Michael Barno, D.C.** **Dr. Zohar Stark, M.D.**

***We are specialized in treating:***

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

**យើងមានជំនាញក្នុងការព្យាបាល :**

☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ រីគី សុន **(215) 380-1350**
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ **(215) 551-6838**

(តមកពីទំព័រទី០១)
# ខ្មែរនៅកាណាដាយកអំណោយ...

ដើម្បីឱ្យសៀមដកកងទ័ពចេញពីអធិបតេយ្យភាពកម្ពុជា ។

ជាមួយគ្នានេះដែរ បងប្អូនខ្មែរដែលរស់នៅប្រទេសផ្សេងៗ បានជួយគាំទ្រទាំងផ្នែកកំលាំងកាយចិត្ត និងសំភារៈ ដើម្បីជួយដល់បងប្អូនខ្មែរដែលរស់នៅតំបន់ជំលោះ និងទាហានដែលកំពុងកាន់អាវុធ ការពារទឹកដីយ៉ាងអង់អាចក្លាហានបំផុត ។

ដើម្បីជាការលើកទឹកចិត្តដល់យុទ្ធជនប្រជាពលរដ្ឋ និងព្រះសង្ឃដែលកំពុងតែមានកាតព្វកិច្ច និងសុខចិត្តបន្តរស់នៅធ្វើជាបង្គោលព្រំដែននោះ មជ្ឈមណ្ឌលព្រះពុទ្ធសាសនា និងវប្បធម៌ខ្មែរនៅទីក្រុង Hamilton ប្រទេសកាណាដា និងសប្បុរសជនទីក្រុងឡុង Maple, Kitchener Guelph និង St. Catharines បានរៃអង្គាសគ្នាបានប្រាក់ចំនួន១ម៉ឺនដុល្លារកាណាដា ។

លោក វីម ឆេង ប្រធានមជ្ឈមណ្ឌលព្រះពុទ្ធសាសនា និងវប្បធម៌ខ្មែរបានមានប្រសាសន៍ថា ទោះបីជាពួកយើងរស់នៅក្រៅប្រទេសពិតមែន ប៉ុន្តែទឹកចិត្តស្នេហាជាតិមាតុភូមិនៅតែដក់ជាប់ក្នុងក្រអៅបេះដូងគ្រប់ពេលវេលា ។ យើងតែងមានអារម្មណ៍ខ្វាយខ្វល់ពីសុខទុក្ខដល់ពលទាហាន ប្រជាពលរដ្ឋ និងព្រះសង្ឃ ដែលកំពុងរស់នៅ និងគង់នោះយ៉ាងខ្លាំងគ្រប់វិនាទី ។

លោក វីម ឆេង បានបន្តថា ក្នុងការស្វែងរកអំណោយផលសំរាប់ឧបត្ថម្ភដល់ពលរដ្ឋដែលរស់នៅតំបន់ប្រាសាទព្រះវិហារ និងខេត្តឧត្តរមានជ័យ (ទាហាន ព្រះសង្ឃ និងពលរដ្ឋនោះ) ក៏មានការចូលរួមសហការពីក្រុមតន្ត្រីករ គឺក្រុមភ្នំពេញ, ក្រុមពិភពតន្ត្រី ក្រុម Forever និងក្រុមសារិកា ដែលបានចូលរួមសំដែងជា


អំណោយបងប្អូនខ្មែរនៅកាណាដា ចែកជូនកងទ័ពនៅប្រាសាទព្រះវិហារ

ច្រើនកន្លែងដើម្បីរៃអង្គាសប្រាក់ ។

លោកប្រធានមជ្ឈមណ្ឌលព្រះពុទ្ធសាសនា និងវប្បធម៌ខ្មែរបានបញ្ជាក់ថា នេះជាទឹកចិត្តដ៏ប្រពៃក្នុងនាមជាខ្មែរដូចគ្នា ដែលបានដុតដៃដុតជើងផ្តល់ជាទឹកប្រាក់ដើម្បីលើកជាកំលាំងដល់បងប្អូនយើងដែលរស់នៅតំបន់នោះ ជាពិសេសយុទ្ធជនការពារព្រំដែន ។

ចំណែកលោក ម៉ម សូណង់ដូ នាយកស្ថានីយវិទ្យុសំបុកឃ្មុំ ដែលបានអញ្ជើញទៅចុះចែកអំណោយរបស់សប្បុរសជននៅប្រទេសកាណាដានោះ បានសំដែងនូវការដឹងគុណ និងជូនពរដល់អ្នកម្ចាស់ទានទាំងអស់ឱ្យជួបតែសេចក្តីសុខ រកស៊ីមានបានក្នុងជីវិតក្រុមគ្រួសារកុំបីអាក់ខានដែលតំណាងឱ្យទាហាន ព្រះសង្ឃ និងប្រជាពលរដ្ឋ នៅតំបន់ប្រាសាទព្រះវិហារ និងខេត្តឧត្តរមានជ័យ កំពុងរង់នូវការឈ្លានពានពីប្រទេសជិតខាង ។

លោក ម៉ម សូណង់ដូ បានបញ្ជាក់ថា អំណោយទាំងនេះពិតជាមានសារប្រយោជន៍ខ្លាំងណាស់សំរាប់បងប្អូនយើងដែលកំពុងប្រឈមមុខជីវភាពខ្វះខាត ហើយទង្វើនេះក៏បានស្តែងឱ្យឃើញពីទឹកចិត្តរបស់ខ្មែរគ្រប់ទិសទី នៅតិតតូរពីស្រុកទេសរបស់ខ្លួន ទោះបីជាឃ្លាតឆ្ងាយយ៉ាងណាក្តី ។ ចំណែកពលរដ្ឋខ្មែរដែលទទួលបានអំណោយគ្រប់វ័យ ក៏មិនភ្លេចគុណចំពោះម្ចាស់ទានដែរ គឺបានបួងសួងឱ្យម្ចាស់ទានរកស៊ីមានបានជារៀងរហូត ហើយប្តេជ្ញាក្រាញនៀលធ្វើជាបង្គោលព្រំដែនមិនរាថយសោះឡើយ ។

គួរបញ្ជាក់ថា ចាប់តាំងពីមានការប្រឈមអាវុធដាក់គ្នានៅតំបន់ប្រាសាទព្រះវិហាររវាងកម្ពុជា-សៀមរួចមក បងប្អូនខ្មែរនៅក្នុងប្រទេស និងក្រៅប្រទេសបានបរិច្ចាគថវិកាជាបន្តបន្ទាប់ជួយដល់យុទ្ធជន ព្រះសង្ឃ និងប្រជាពលរដ្ឋនៅតំបន់នោះ ដើម្បីរួមចំណែកក្នុងបុព្វហេតុជាតិមាតុភូមិ ។

ជាពិសេសនោះ បងប្អូនខ្មែរនៅកាដាណា បារាំង អាមេរិក អូស្ត្រាលី... បាននាំគ្នាធ្វើការតវ៉ានៅអង្គការសហប្រជាជាតិរឿងសៀមឈ្លានពានប្រទេសកម្ពុជា និងនាំគ្នាធ្វើការរៃអង្គាសជាថវិកាយកជួយខ្មែរក្នុងស្រុកជាបន្តបន្ទាប់ គួរឱ្យគោរពកោតសរសើរខ្លាំងណាស់ ។

គួរបញ្ជាក់ថា ដោយសារតែគ្មានប្រព័ន្ធមនាគមសប្បុរសជនខ្មែរនៅក្រៅប្រទេសបានចូលលុយជាបន្តបន្ទាប់កសាងផ្លូវឆ្ពោះទៅកាន់ប្រាសាទតាមាន់ដែលពេលនេះជិតរួចហើយ ដែលទង្វើនេះប្រពៃខ្លាំងណាស់សំរាប់ជាតិសាសន៍ខ្មែរយើងតាំងពីសម័យបុរាណម្លេះ ៕

មាជ សុវណ្ណារ៉ា,



You are invited
to Join
Christmas Eve
Party
Win Raffle Prizes!
Free Food
Sing Cambodian,
Chinese & Viet-
namese
Karaoke.
When: 12/24th
Time: 10:00 a.m.
to
12:30 p.m.

## Merry Christmas & Happy New Year!

សូមអញ្ជើញលោកអ្នកមកចូលរួមជប់លៀងថ្ងៃ "គ្រិស្តមីសអ៊ីវ" ចាប់ឆ្នោតវត្ថុយករង្វាន់ !
ពិសារភោជនីយាហារឥតគិតថ្លៃច្រៀងចំរៀងខ្មែរ ចិន និង វៀតណាម មានខារ៉ាអូខេ
ថ្ងៃណា ? ថ្ងៃ ២៤ ខែ ធ្នូ
ម៉ោងប៉ុន្មាន ? ពីម៉ោង ១០ ព្រឹកដល់ ១២កន្លះ រសៀល

Nationalities
Senior Center
4837 N. Marvine
Street
Philadelphia, PA
19141
(215)324-7554

នៅមជ្ឈមណ្ឌលព្រឹទ្ធាចារ្យគ្រប់សញ្ជាតិ
4837N MARVIN Street .
Philadelphia . PA 19141
ទូរស័ព្ទ : 215 324-7554

## បន្ទប់បរិយាកាស សូមពិសាភេសជ្ជៈមួយកែវ នៅបារ៍ TIPSY

ជាហាងកូនខ្មែរធំទើបបំផុត នៅតំបន់ហ្វីឡាខាងជើង
ធិបស៊ី មាន "បារ៍" មាន "ឡោនជ៍"
ទទួលភ្ញៀវនឹងរាំកំសាន្តយ៉ាងសប្បាយរីករាយ



ធិបស៊ី នឹងនាំឱ្យលោកអ្នកចង់រាំកំសាន្ត

Live D.J. every Fri & Sat night from 9 p.m. – 2 p.m. (pool table)
Serve Chinese and American food open for Lunch and Dinner
មានក្រុមតន្ត្រីសម័យ ឬ DJ ចាក់ចម្រៀងពិរោះៗឱ្យស្តាប់រៀងរាល់រាត្រី ថ្ងៃសុក្រ_ថ្ងៃសៅរ៍ ពីម៉ោង ៩ យប់ ដល់ម៉ោង ២ ភ្លឺ
មានតុបុកប៊ីយ៉ាទៀតផង

Ralph Rinn
Tel: 215.305.5763
Cell: 267.968.3413
Michael Lay (General Manager)
215.409.4772
Email: tipsybar@gmail.com

Sun-Thu: 10 – 12 a.m.
Fri & Sat: 10 – 2 a.m.
Kitchen Open Daily
Sun-Sat: 10 – 11 p.m.
3904 Frankford Ave.
Philadelphia, Pa 19124

## Nationwide

Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រង សុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase
Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

## ឱកាសសំរាប់ជាម្ចាស់ការលើមុខរបរ សំអាតការិយាល័យ

STRATUS BUILDING SOLUTIONS
Rapid Growing Commercial Cleaning Industry



មុខរបរដែលនរណាក៏អាចធ្វើបាន ឱ្យតែមានការព្យាយាម ហើយចង់បានប្រាក់ច្រើន ។ "ស្ត្រាតឹស" គឺជាឱ្យស្សាហកម្មមួយដែលកំពុងរីកចំរើន នៅ ស.រ.អា យើងនឹងផ្តល់ជូននូវ :

- ការហាត់ហ្វឹកហ្វឺនពីមុខរបរនោះ
- យើងជួយឱ្យមុខរបរនោះឱ្យដំណើរការ
- យើងជួយរកទីផ្សារនឹងគ្រប់គ្រងមុខរបរជូន

លោកអ្នកអាចផ្តើមមុខរបរ ដោយមានភ្ញៀវរួចជាស្រេចជាមួយនឹងការងារដែលលោកអ្នកធ្វើបានយ៉ាងងាយស្រួលដោយ :

- យើងផ្តល់ឱកាសសំរាប់ផ្តើមការងារ
- លោកក្លាយជាម្ចាស់នៃការងារ ដោយដាក់ទុនយ៉ាងតិចតួច ដូចជា: ១000 ដុល្លារ
- ធ្វើការតាមពេលដែលលោកអ្នកមាន
- លោកអ្នកត្រូវមានយានជំនិះដែលអាចទុកចិត្តបាន

បើចង់ជ្រាបច្បាស់លើសពីនេះ សូមទាក់ទងទូរស័ព្ទ
ទៅ ចន ខនម៉ាន់ (២១៥) ២៧២_៥៥៣៦
ឬហៅរ៉េត សុបិន (២៦៧) ២៥៣_៣៩៤៧

120 GIBRALTAR RD. STE. 109. HORSHAM, PA 19044

# (តមកពីទំព័រទី០១) ខ្មែរ-អាមេរិកាំងជាង២៥០នាក់...

និងជំរុញឱ្យប្រទេសសៀមគោរពនូវបូរណភាពទឹកដីរវាងប្រទេសទាំងពីរ ។

ផ្ទាំងបដា ដែលសរសេរជាអក្សរបាលីយ៉ាងធំៗ ថា : " នត្ថិ សន្តិ បរំ សុខំ " ឬ " គ្មានក្តីសុខឯណាប្រសើរជាងសន្តិភាព " ត្រូវបានលើកតាំងនៅចំពោះមុខអាគារដ៏ធំស្កឹមស្កៃ ដែលអ្នកផងទាំងពួងស្គាល់យ៉ាងច្បាស់ថា ជាទីស្នាក់ការកំពូលរបស់អង្គការសហប្រជាជាតិ ចាប់តាំងពីព្រលឹមម៉ោង ១១:៣០ និងត្រូវបានទម្លាក់វិញនៅម៉ោង ៣:៣០រសៀល ។

ក្រៅពីនោះ ក៏នៅមានផ្ទាំងបដាតូចៗជាច្រើនទៀត ត្រូវបានអ្នកចូលរួមកាន់ និងអ្នកខ្លះទៀតពាក់ជាប់នឹងក ដែលសរសេរជាខេមរភាសា និងភាសាអង់គ្លេស ដែលរាល់បដានិមួយៗ សុទ្ធសឹងមានន័យចង់បានសន្តិភាព មិនចង់ឱ្យមានការផ្ទុះអាវុធ និងសុំឱ្យសៀមគោរពនូវបូរណភាពទឹកដីរវាងប្រទេសទាំងពីរជាដើម ។

ក្រោយពេលដែលព្រះសង្ឃសូត្រជយន្តោ ព្រះភិក្ខុសង្ឃ សៅ ឃិន ធម្មថេរោ បានអាននូវសេចក្តីថ្លែងការណ៍ពីរទំព័រ និងមានបីចំណុចសំខាន់ៗជូនអង្គពិធី ដែលមានខ្លឹមសារទាំងស្រុងយ៉ាងដូច្នេះ :

១. មកចូលរួមចំណែកក្នុងការរំលឹកទិវាសិទ្ធិមនុស្សសកលឆ្នាំទី៦០ ១០ធ្នូ ១៩៤៨ ព្រមទាំងអបអរសាទរការចូលជាសមាជិកនៃអង្គការសហប្រជាជាតិ នៃប្រទេសជាតិ មាតុភូមិយើង ថ្ងៃទី១៤ ធ្នូ ឆ្នាំ១៩៥៦ ។

២. អំពាវនាវជាទៅទូ សុំឱ្យប្រទេសសមាជិកអង្គការសហប្រជាជាតិទាំងអស់ និងជាពិសេសប្រទេសហត្ថលេខីទាំងអស់នៃសន្ធិសញ្ញាសន្តិភាពកម្ពុជា នាក្រុងប៉ារីស ១៩៩១ ឱ្យចាប់អារម្មណ៍ និងស្វែងរកដំណោះស្រាយជាបន្ទាន់ ចំពោះការរំលោភសិទ្ធិមនុស្ស និងបូរណភាពទឹកដី មាតុភូមិ






កម្ពុជាយើង ពីសំណាក់បរទេសជិតខាង ដូចជាប្រទេសថៃជាដើម ដែលបណ្តាលឱ្យមានអសន្តិសុខយ៉ាងខ្លាំងក្លាដល់ជីវិតមហាជនខ្មែរ និងការបដិបត្តិព្រះពុទ្ធសាសនារបស់ព្រះសង្ឃខ្មែរយើង ដែលមាននៅនឹងវត្តអារាមនានា នៅតាមព្រំដែន ដូចជា នៅតំបន់ប្រាសាទព្រះវិហារជាដើម ។

៣. រំលឹកប្រទេសថៃថា គប្បីប្រទេសយើងទាំងពីរអាចរស់នៅជិតគ្នាដោយសុខសប្បាយណាស់ ព្រោះប្រទេសថៃ និងកម្ពុជា ជាប្រទេសសមាជិករបស់អង្គការសហប្រជាជាតិដូចគ្នា ជាប្រទេសសមាជិកមិនចូលបក្សសម្ព័ន្ធដូចគ្នា ជាប្រទេសសមាជិកសមាគមប្រទេសអាស៊ីអាគ្នេយ៍ដូចគ្នា ហើយជាពិសេស យើងជាប្រទេសកាន់ព្រះពុទ្ធសាសនាដូចគ្នា ។

ក្រៅអំពីការនិមន្តចូលរួមពីសំណាក់ព្រះសង្ឃចំនួនជាង ២០អង្គ មកពីបណ្តាវត្តផ្សេងៗក្នុងសហរដ្ឋអាមេរិកហើយនោះ ក៏នៅមានអ្នកចូលរួមគាំទ្រជា ២៥០នាក់ មកពីបណ្តារដ្ឋមួយចំនួន ដូចជា រដ្ឋផែនស៊ីវ៉ៃនៀ ( ហ្វីឡាដែលហ្វៀ ), ញូវចឺស៊ី, ញូវយ៉ក, រ៉ូដអាយឡែន, ម៉ាស៊ីឡែន, ម៉ាសាឈូសេត និង វ៉ាស៊ីនតោនឌីស៊ី ជាដើម ។

ដោយឡែកតំណាងគណបក្សនយោបាយមួយចំនួន ដូចជាគណបក្សសិទ្ធិមនុស្ស និងគណបក្សសម រង្ស៊ី ក៏មានវត្តមានក្នុងពិធីធម្មយាត្រាសន្តិភាពនោះដែរ ។ ចំណែកលោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស និងជាអ្នកតំណាងរាស្ត្រទើបជាប់ឆ្នោត ក៏បានចូលរួមកាន់បដាក្រោមតំណក់ភិរុណ នាឱកាសនោះដែរ ។

ដូនចាស់ ចាប ឡាន មកពីទីក្រុងឡូវ៉ែល ដែលបានចូលរួមក្នុងក្បួនធម្មយាត្រានោះ បានប្រាប់ខ្មែរប៉ុស្តិ៍ ទាំងសម្លេងញ័រខ្សាវៗថា : លោកយាយមិនសុខចិត្តទេ ចំពោះការឈ្លានពានពីសំណាក់សៀម ហើយការដែលលោកយាយមកនេះ គឺចង់ស្នើដល់អង្គការសហប្រជាជាតិដើម្បីបង្ខំឱ្យសៀមចាក់ចេញពីស្រុកខ្មែរទាំងអស់ កុំឱ្យឈ្លានពានប្រទេសខ្មែរទៀត ។

ចំណែកលោក អ៊ូ ផានអ៊ុ មកពីរដ្ឋម៉ារីឡែន បានថ្លែងប្រាប់ខ្មែរប៉ុស្តិ៍ ទាំងទឹកមុខមាំថា : លោកជាអ្នកទ្រទ្រង់យុត្តិធម៌ ដូច្នេះ សៀមជាអ្នកឈ្លានពានមកលើប្រទេសខ្មែរ ហើយទឹកដីខ្មែរ ក៏មិនត្រូវឱ្យនរណាមកជ្រៀតជ្រែក មករំលោភបំពានបានឡើយ ព្រោះជាទឹកដីតាំងពីដូនតារបស់យើងមក ហើយយើងក៏មិនដែលយកពីនរណាមកដែរ ។

សូមជម្រាបផងដែរថា អង្គពិធីបានប្រព្រឹត្តទៅយ៉ាងល្អរលូន ដោយពុំមានការរារាំង ឬរំខានណាមួយពីសំណាក់សមត្ថកិច្ចប៉ូលីសឡើយ ហើយពលរដ្ឋខ្មែរ នៅហ្វីឡាដែលហ្វៀ ត្រូវបានចូលរួមច្រើនជាងរដ្ឋនានាទាំងអស់ ដោយមានចំនួនរហូតដល់ ៧០នាក់ និងមានការនិមន្តចូលរួមដោយព្រះសង្ឃគង់នៅវត្តព្រះពុទ្ធរង្សី វត្តបាលិលេយ្យ និងវត្តសុរិយារង្សី ៕

**អ៊ឹម លឿម**

wishing our Friends in the Cambodian Community

Happy Holidays!

សូមជូនពរដល់លោកអ្នកជាទីរាប់អានទាំងអស់នៅសហគមន៍ខ្មែរ រីករាយនាឱកាសបុណ្យឈប់សំរាក !

Law Office
Harrington & Harrington
Rising Sun Avenue & Olney Avenue
215-324-7779
Cambodian Speaking Staff

- Auto Accident
- Work Injuries
- Traffic Tickets
- Driver License Suspension

- ▸▸ គ្រោះថ្នាក់រថយន្ត
- ▸▸ របួសនៅកន្លែងធ្វើការ
- ▸▸ ផាកដោយចរាចរ
- ▸▸ ដកហូតលិខិតបើកបរ

Randolph C. Smith



សុធា

Attorney at Law

267-324-6503

Office # 1
1819 JFK Blvd.
Philadelphia, Pa 19103

Office # 2
1115 S. 11th St.
Philadelphia, Pa 19147

ការិយាល័យច្បាប់យើងខ្ញុំ មានជំនាញខាងករណី គ្រោះថ្នាក់រថយន្ត
☞ មានរបួសនៅកន្លែងធ្វើការ ☞ បើកបរក្រោមឥទ្ធិពលស្រវឹង
☞ ករណីព្រហ្មទណ្ឌ និងអន្តោប្រវេសន៍ យើងនឹងយកចិត្តទុកដាក់ពីរថយន្តពីអ្វីទាំងអស់ដោយមិនឱ្យលោកអ្នកចំណាយប្រាក់ខ្លួនឯងឡើយ ។
បើចង់ដឹងអ្វីបន្ថែមសូមហៅរក សុធា : (267) 324-6503

We are specialty in Car Accident, Work Injury, DUI, Criminal Matter, and Immigration.

We will take care of your car and everything else without your pocket expense.

Please contact Sothia at 267-324-6503 for more information.

(តមកពីទំព័រទី០២) **កម្ពុជាជំពាក់បំណុលបរទេស...**

គ្មានតម្លាភាព ដែលធ្វើឱ្យប្រជាពលរដ្ឋកម្ពុជា មិនទាន់ដឹងក្តីក៏ជំពាក់បំណុលបរទេសដែរ ។ ដូច្នេះមិនដឹងប៉ុន្មានឆ្នាំទៀត ទើបខ្មែរយើងរួចបំណុលបរទេស បើអ្នកដឹកនាំមិនព្រមអនុម័តច្បាប់ប្រឆាំងអំពើពុករលួយនោះ ។

លោក សុន ឆ័យ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី ធ្លាប់បានរិះគន់ចំពោះរដ្ឋាភិបាល ហ៊ុន សែន ពីការចាយវាយថវិកាខ្ជះខ្ជាយ និងយកទៅអភិវឌ្ឍន៍ឱ្យចំទិសដៅ ហើយធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាម្នាក់ៗត្រូវជំពាក់បំណុលបរទេសរាប់ពាន់ដុល្លារទៀត ។

ទោះបីជាមានការរិះគន់ចំៗពីគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិលពីការជំពាក់បំណុលបរទេស ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន យ៉ាងណាក្តី កាលពីខែតុលា ឆ្នាំ2007 ហ៊ុន សែន បានខ្ចីលុយពីចិនចំនួន 280លានដុល្លារបន្ថែមទៀត សំរាប់យកមកទ្រទ្រង់អំណាចរបស់ខ្លួន ។

នៅថ្ងៃទី3ដល់ថ្ងៃទី5 ខែវិច្ឆិកា រដ្ឋាភិបាល ហ៊ុន សែន បានរៀបចំឯកសារសុំជំនួយពីសហគមន៍អន្តរជាតិ និងក្រុមប្រទេសអ្នកផ្តល់ជំនួយសំរាប់ចាយវាយក្នុងឆ្នាំ 2009 ។

ក្នុងកិច្ចប្រជុំប្រទេសអ្នកផ្តល់ជំនួយនោះបានផ្តល់ថវិកាជិត 1000លានដុល្លារ ដែលជំនួយនោះច្រើនជាងឆ្នាំកន្លងមក ។

គួររំលឹកថា ប្រទេសអ្នកផ្តល់អំណោយទាននឹងផ្តល់ឱ្យ ហ៊ុន សែន ក្រោមលក្ខខណ្ឌមួយដូចសព្វមួយដងអ៊ីចឹង ប៉ុន្តែ ហ៊ុន សែន មិនសូវបានអនុវត្តតាមនោះទេ ។

លោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិយាយជាសាធារណៈថា យើងមិនដឹងថា នៅពេលណាកម្ពុជាឈប់ខ្ចីបុលជំនួយពីបរទេសនោះទេ ។ ការលើកឡើង បែបនេះធ្វើឱ្យមហាជនយល់ថា កម្ពុជាពុំទាន់មានលទ្ធភាពរកលុយបានដោយខ្លួនឯងទេ ហើយកម្ពុជានៅខ្ចីដង្ហើមគេដកនៅឡើយ ។ ជាពិសេស បង្ហាញពីអសមត្ថភាពរបស់អ្នកដឹកនាំមួយចំនួនផងដែរ ។

ទាក់ទងទៅនឹងជំនួយបរទេសនេះគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានធ្វើសន្និសីទកាសែតរួមគ្នាឱ្យម្ចាស់ជំនួយនិងដៃគូ ។

លោក សុក សំអឿន នាយកប្រតិបត្តិអង្គការតំរោងអ្នកការពារច្បាប់សិទ្ធិកម្ពុជា បានឱ្យដឹងថា ដោយសារតែអំពើពុករលួយ និងការចាយវាយក្រោមតុសំរាប់សេវារត់ការ ទើបធ្វើឱ្យមនុស្សមួយចំនួនមានទំលាប់មិនល្អ ។ កន្លងមកលោកធ្លាប់បានចូលរួមជាមួយអង្គការសង្គមស៊ីវិលជាង៤០ នាំស្នាមមេដៃប្រជាពលរដ្ឋមន្ត្រីរាជការជាង1លាននាក់ឱ្យរដ្ឋសភា ដើម្បីជំរុញឱ្យរដ្ឋសភាអនុម័តច្បាប់នេះឱ្យបានឆាប់ ។

លោក សុក សំអឿន បន្តថា កាលណោះសភាគ្រាន់តែទទួលយកញ្ញត្តិរបស់អង្គការសង្គមស៊ីវិលទេ ហើយមិនព្រមទុកស្នាមមេដៃ ឡើយពីព្រោះខ្លាចចង្អៀតកន្លែង រហូតមកដល់ពេលនេះ បើតាមលោកដឹងសេចក្តីព្រាង ច្បាប់នេះនៅទើរត្រឹមទីស្តីការគណៈរដ្ឋមន្ត្រីនៅឡើយ ។

គួរបញ្ជាក់ថា ក្នុងមួយថ្ងៃរដ្ឋត្រូវចំណាយលុយក្រោមតុអស់ជាង1លានដុល្លារ ហើយតាមរយៈរបាយការណ៍របស់ USAID និងអង្គការតម្លាភាពបានរកឃើញអំពើពុករលួយក្នុង1ឆ្នាំរដ្ឋត្រូវខាតបង់អស់លុយជាង 500លានដុល្លារ ដែលស្មើនឹងជំនួយរបស់សហ គមន៍អន្តរជាតិ ។

ដោយសារតែរដ្ឋាភិបាល ហ៊ុន សែន មិនព្រមអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ពីព្រោះខ្លាចប៉ះពាល់ដល់មន្ត្រីខិលខូចរបស់ខ្លួននេះហើយ ទើបធ្វើឱ្យថវិការដ្ឋត្រូវមន្ត្រីមួយចំនួនដកហូតចាយស្រេចតែចិត្ត បង្កឱ្យអំពើពុករលួយរីករាលដាល និងជំពាក់បំណុលគេ រីឯ្ណ.ក ដែលកូនចៅខ្មែរគ្រប់រូបជាអ្នកសងជំនួស គួរអយុត្តិធម៌ខ្លាំងណាស់ ៕






នាទី ប្រវត្តិសាស្ត្រ

# ទំព័រប្រវត្តិដែលប្រឹយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយ : ពិនសំខុន** ***តពីលេខមុន***

**៦ សីហា ឆ្នាំ១៩៦២ :**

•••រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី១៨ ដឹកនាំដោយចៅសែន កុសល បញ្ចាវន្តបីរូប ដែលក្រោយមកចូលរួមក្នុងចលនាខ្មែរក្រហម គឺ ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម ក៏នៅក្នុងសមាសភាពនោះដែរ ។

**១៨. រដ្ឋាភិបាល ចៅសែន កុសលឈុំ (៦.៨.១៩៦២-៦.១០.១៩៦២)**

. នាយករដ្ឋមន្ត្រី : ចៅសែន កុសលឈុំ
. ទេសរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ : លន់ ណុល
. រដ្ឋមន្ត្រីកសិកម្ម : យ៉ែម សំបូរ
. រដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៍ : ផ្លែក ភីន
. រដ្ឋមន្ត្រីការបរទេស : ហួត សម្បត្តិ
. រដ្ឋមន្ត្រីសាធារណសុខាភិបាល : អ៊ឹង ហុងសាត
. រដ្ឋមន្ត្រីព័ត៌មាន : ទ្រិញ វ៉ាញ
. រដ្ឋមន្ត្រីផែនការ : សឹង ភឿកថ
. រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ហ៊ូ យន់
. រដ្ឋមន្ត្រីពាណិជ្ជក ម្ម : ហ៊ូ នឹម
. រដ្ឋមន្ត្រីយុត្តិធមិ : ភី ធៀនឡាយ
. រដ្ឋមន្ត្រីមហាផ្ទៃ : អុប គីមអាង
. រដ្ឋមន្ត្រីអប់រំជាតិ-យុវជន និងវិចិត្រសិល្បៈ : ម៉ែន ឈុំ
. រដ្ឋមន្ត្រីឧស្សាហកម្ម : យ៉ុង យុន
. រដ្ឋមន្ត្រីសង្គមកិច្ច និងការងារ : ហ៊ែល ស៊ុំផា
. រដ្ឋមន្ត្រីធម្មការ- ទទួលបន្ទុកទំនាក់ទំនងជាមួយសភា : គុយ ពៅ
. អនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស : សាក់ ស៊ុតសាខន

**ថ្ងៃទី២០សីហា :**

សម្តេចសីហនុបានអំពាវនាវដល់ប្រមុខរដ្ឋាភិបាលប្រទេសសុំឱ្យទទួលស្គាល់ និងធានាអព្យាក្រិតភាព និងបូរណភាពទឹកដីកម្ពុជា និងប្រទេសបារាំង, ចិន, រុស្ស៊ី, វៀតណាម ខាងជើងបានឆ្លើយតប ហើយទទួលស្គាល់មុនគេ ។

**ថ្ងៃទី២តុលា :**

នៅអង្គការសហប្រជាជាតិ តំណាងប្រទេសថៃ បានទាមទារយកខេត្តបាត់ដំបង, កំពង់ធំ, សៀមរាប ពីកម្ពុជា ។

**ថ្ងៃទី៦តុលា :**

សម្តេចសីហនុ បានប្តូររដ្ឋាភិបាលថ្មីមួយទៀត ជំនួសដោយទ្រង់នរោត្តម កន្តុល ។

( នៅមានត )


SUNSHINE JEWELRY, INC.

- Fine Jewelry
- Certified Diamonds & Custom Design




**Holiday Specials!**

- Up to 50% of on selected diamond jewelry
- SEIKO Watches--25% off on all SEIKO watches
- Special Limited Time Holiday Promotion! 3 Months up to 6 months NO INTEREST.

* Offer is subject to credit approved by GE Money Bank.
Promotional applies to all purchase amounts.
P romotional begins now through January 31, 2009.
See store for details or call.*

**លក់ចុះថ្លៃពិសេសនាឱកាសបុណ្យ**

- អាចបញ្ចុះរហូតដល់ 50% នៅលើពេជ្រដែលជ្រើសរើស
- ចុះថ្លៃ 25% លើគ្រប់នាឡិកា "សៃកូ"
- ចុះថ្លៃពិសេសកំណត់ថ្ងៃបុណ្យ ! ពី៣ខែ រហូត ៦ ខែ គ្មានយកការប្រាក់

យើងអាចសុំឱ្យក្រេឌីត នៅ G.E Money Bank បាន សំរាប់គ្រប់ដែលទិញរួមគ្នា ផ្តើមទៅនេះបញ្ចប់នៅថ្ងៃ ៣១ មករា ឆ្នាំ ២០០៩ សូមទូរស័ព្ទរកយើង បើចង់ដឹងបន្ថែម

702 Washington Avenue Phone: (215) 271-2950
Philadelphia, Pa 19147 Fax: (215) 271-2962
Email: colorofsunshine@yahoo.com


នាទី ព្រះពុទ្ធសាសនា

# សមាធិវិបស្សនា អវសានកថា

**ដោយ : ពិន សំខុន**

***តពីលេខមុន***

❖❖❖នៅលេខចុងក្រោយប្រចាំឆ្នាំ២០០៨នេះ យើងបញ្ចប់អត្ថបទ វិប្បសនាកម្មដ្ឋានតែត្រឹមនេះសិន ហើយចង់បង្រួមសេចក្តីដូចតទៅ :

វិប្បសនាកម្មនេះ គឺជាបច្ចេកវិជ្ជាបង្រៀនដោយព្រះសម្មាសម្ពុទ្ធ សម្មាណគោត្តម តាំងពីជាង ២៥០០ឆ្នាំមកហើយ ។ បច្ចេកវិជ្ជានេះមានដើម កំណើតនៅប្រទេសឥណ្ឌា ហើយហូរចូលមករក្សានៅប្រទេសភូមា រហូតដល់ចុងក្រោយបង្អស់នេះ សិស្សច្បងម្នាក់ឈ្មោះ ហ្គោឥនកា ជនជាតិឥណ្ឌា កើតនៅភូមា បានសិក្សា ហើយផ្សព្វផ្សាយវិប្បសនាកម្មដ្ឋាននៅពាសពេញសកលលោកនេះឡើងវិញ តាំងតែប្រមាណជា ៥០ឆ្នាំមកហើយ ។

បច្ចេកវិជ្ជារបស់ព្រះពុទ្ធជាម្ចាស់ បានត្រូវផ្សព្វផ្សាយ ហើយអនុវត្តន៍ក្នុងរូបភាពដើម ដែលបានថែទុកជាង ២៥០០មកហើយនោះ ច្រើនភាសានៅស្រទាប់មនុស្សគ្រប់សញ្ជាតិ និងក្នុងរង្វង់នៃគ្រប់សាសនា ដោយគ្មានការប្រកាន់ ឬទំនាស់អ្វីឡើយ ។ លទ្ធផលបានត្រូវទទួលវិញដូចៗគ្នាទាំងអស់ : ការរំងាប់ទុក្ខបានបង្កើតចិត្តសទ្ធាជ្រះថ្លា បង្កើតនូវចំណេះភ្លឺថ្លា បង្កើតនូវចរន្តគោរពសីលធមិ និងគុណប្រយោជន៍ផ្ទាល់ខ្លួនច្រើនទៀត ចំពោះអ្នកដែលបានប្រារព្ធបច្ចេកវិជ្ជានោះ ឱ្យបានហ្មត់ចត់ យ៉ាងហោចណាស់ក្នុងរយៈពេល ១០ថ្ងៃ ឱ្យបានម្តង ។

ចាប់ពីឆ្នាំ ២៥០០ នៃពុទ្ធសាសនាមក បច្ចេកវិជ្ជានេះ បានត្រូវបង្រៀនដល់មនុស្សច្រើនលាននាក់ហើយ ហើយប្រទេសឥណ្ឌា មុនគេបង្អស់ បានយកបច្ចេកវិជ្ជាដ៏ឧត្តមនេះ ទៅផ្តល់ដល់អ្នកដែលមានទុក្ខ គឺឧក្រិដ្ឋជនសាហាវខ្លាំង ឬតិច ដែលកំពុងទទួលទោសនៅក្នុងពន្ធនាគារ ។ គុក "ទីហា" នៅឥណ្ឌា បានទទួលអ្នកទោសស្ម័គ្រចិត្តរាប់ម៉ឺន នាក់ ជារៀងរាល់ឆ្នាំ ហើយនាយិកាគុកនោះ បានទទួលស្គាល់ពីប្រសិទ្ធភាពដ៏អស្ចារ្យរបស់វិប្បសនាកម្មដ្ឋាន សំរាប់អ្នកទោសសម្លាប់មនុស្ស, អ្នកទោសដោយគ្រឿងញៀន, ស្ត្រីពេស្យា ។ល។

ឥឡូវនេះ សហរដ្ឋអាមេរិកកំពុងតែផ្តោតអារម្មណ៍ទៅលើការពិសោធន៍វិប្បសនានេះ នៅពន្ធនាគារសំខាន់ៗជាច្រើន ។ ចុងក្រោយបង្អស់ គុកដ៏មាំមួយ នៅអាឡាបាម៉ា បានត្រូវបច្ចេកវិជ្ជាព្រះសម្មាណគោត្តម បានចូលទៅដល់ ហើយបានសង្គ្រោះមនុស្សមួយចំនួនរួចហើយ ក្នុងគោលបំណង គឺបង្រ្កាបអំពើហឹង្សា អបាយមុខអវិជ្ជាឱ្យបានជាក់ស្តែង ហើយអ្វីដែលហៅថាកុសលផលបុណ្យ បានកើនឡើងយ៉ាងទាន់ហន់ ដូចគ្នានឹងកាលជំនាន់ព្រះពុទ្ធ លោកបានប្រោសអង្គុលីមារ និងនាងបដាចារ ដូច្នោះឯង ។

ការអនុវត្តន៍នូវវិជ្ជាវិប្បសនានេះ ពុំចាំបាច់ចេះសូត្រធមិតាមព្រះពុទ្ធសាសនាទេ តែក្នុងរយៈពេលអនុវត្តន៍កម្មវិធីនោះ គ្រូបង្ហាត់ជំនួយលោកគ្រូហ្គោឥនកា នឹងជួយពន្យល់ពីហេតុផលនៃការប្រែប្រួលនៅក្នុងរូបរាងកាយនៃបុគ្គលម្នាក់យ៉ាងហ្មត់ចត់ និងប្រុងប្រយ័ត្ន ហើយកម្មវិធីនេះទៀតសោត បានត្រូវលាតសន្ធឹងដល់កុមារតូចៗ ដែលឪពុកម្តាយនិយាយថា " បន្ទាប់ពីកូនគាត់ចូលធ្វើវិប្បសនាកម្មដ្ឋាន ( កម្មវិធីពេលខ្លី ) កូនគាត់មានការងាយស្រួលនឹងប្រៀនប្រដៅ ហើយរៀនសូត្រក៏បានកើតស្មារតីទៀតផង " ។

នៅសហរដ្ឋអាមេរិក កាណាដា បារាំង អូស្ត្រាលី សហគមន៍ខ្មែរយើង បានចូលរួមក្នុងចលនាវិប្បសនាកម្មដ្ឋាន ហើយអ្នកទាំងនោះបានមើលឃើញ ចលនាព្រះពុទ្ធសាសនា នៅតាមវត្តអារ៉ាមមានខុសឆ្គងជាច្រើនអន្លើ ជាពិសេសជាមួយព្រះសង្ឃនៅទីវត្ត ដែលពុំគោរពវិន័យសង្ឃឱ្យបានត្រឹមត្រូវខ្ជាប់ខ្ជួន ។ នៅក្នុងសហរដ្ឋអាមេរិកនេះ មេដឹកនាំធំៗនៃចលនាវិប្បសនាហៅ MAVA បានមើលឃើញថា ហ៊្វិឡាដែលហ្មៀជាចំណុចសំខាន់របស់ពួកគេ ហើយណាត់គ្នាមករួមប្រជុំប្រចាំឆ្នាំ យ៉ាងស្ងៀមស្ងាត់ច្រើនដងមកហើយ ។ មេចលនាទាំងនោះ ពុំមានសញ្ញាណាមួយ ដែលខុសប្លែកពីអ្នកដទៃនោះទេ ក៏ប៉ុន្តែចរិតបូកពារ ភាពជ្រះថ្លា បរិសុទ្ធ និងលះបង់ចំពោះអ្នកដទៃ បានបង្ហាញច្បាស់គួរឱ្យគោរពនៅពេលចាំបាច់ម្តងៗ ។

លោកអ្នកអានជាទីគោរពរាប់អាន ខ្មែរប៉ុស្តិ៍ បានចំណាយពេលប្រាំខែ សំរាប់បង្ហាញអំពីរង្វាន់ដ៏ថ្លៃថ្លារបស់ព្រះសម្មាណគោត្តម ដល់មនុស្សជាតិ ដោយមិនប្រកាន់ពូជសាសន៍ ឬពណ៌សម្បុរ គឺវិប្បសនាកម្មដ្ឋាន ពីលេខក្រោយតទៅ យើងនឹងជូនពុទ្ធប្រវត្តិ ដោយរូបភាពជាភាសាខ្មែរ និងអង់គ្លេស ៕

**សួស្តីឆ្នាំ ២០០៩ !**

**វេបសាយអង្គការវិប្បសនាកម្មដ្ឋាន :**

**www. dhamma.org .**

# សារបដិសេធ

**Rorng Sorn disclaiming the message printed on November 1, 2008, supporting Barack Obama. i just wanted to reiterate than i'm supporting Barack Obama on an individual basis, not as CAGP staff. My title and affiliation, along with my picture were prited without my knowledge; therefore, I am disclaiming it.**

អ្នកស្រី រ៉ង ស៊ន បានបដិសេធសារ កាលពីថ្ងៃទី១ វិច្ឆិកា ២០០៨ ដែលបានគាំទ្រដល់លោក បារ៉ាក់ អូបាម៉ា "ខ្ញុំចង់បញ្ជាក់ថា ខ្ញុំបានគាំទ្រលោក បារ៉ាក់ អូបាម៉ា ក្នុងនាមជាឯកជនប៉ុណ្ណោះ ពុំមែនក្នុងនាមជាបុគ្គលិកសមាគមខ្មែរ CAGP ទេ តួនាទីរបស់ខ្ញុំ និងកន្លែងធ្វើការភ្ជាប់ជាមួយរូបថត បានបោះពុម្ពដោយខ្ញុំពុំបានដឹងជាមុន ហេតុនេះហើយ ខ្ញុំមិនទទួលស្គាល់ចំពោះសារនោះទេ "៕

(តមកពីទំព័រទី០៩)

# ដីខ្មែរផ្ទះយួន...

តាំងលំនៅច្រើនម្តុំផ្សារច្បារអំពៅ ផ្សារតាខ្មៅ គីឡូម៉ែត្រលេខ 7, 8 និង 9 ។ល។

ចំណែកឯនៅតាមខេត្ត ពួកនិគមយួនច្រើនតាំងលំនៅតាមទីប្រជុំជន និងដងទន្លេ ស្ទឹង កើតកូនចៅកាន់តែច្រើនគួរឱ្យព្រួយបារម្ភ ហើយពួកនោះមានសិទ្ធិបោះឆ្នោតទៀតផង ។


ង្វៀង ធីឌីក ដើរទិញអេតចាយនៅតាមផ្ទះ


ទិដ្ឋភាពផ្ទះជនជាតិយួន នៅផ្សារក្រោម ខេត្តកំពង់ឆ្នាំង

ជាឧទាហរណ៍ ពួកយួនបាននាំគ្នាសង់ផ្ទះលើទូកនៅម្តុំផ្សារក្រោម និងតំបន់ឆ្នុកទ្រូ ខេត្តកំពង់ឆ្នាំង ច្រើនណាស់។ ពួកគេទាំងនោះថែមទាំងបង្កើតជាសមាគម និងរារាំងមិនឱ្យខ្មែរយើងទៅនេសាទនោះទេ ។

លោក ស្រ៊ុន ម៉េងហ៊ាង ជាសមាជិកគណ-បក្ស សម រង្ស៊ី បានឱ្យដឹងថា នៅខេត្តកំពង់ឆ្នាំង ពួកយួនបាននាំគ្នាមកតាំងលំនៅកាន់តែច្រើន និងប្រកបរបរដូចពលរដ្ឋខ្មែរអ៊ីចឹង ។ ពួកនេះខ្លះក៏មានប័ណ្ណគ្រួសារ និងខ្លះទៀតមិនមានទេ ប៉ុន្តែខាងអាជ្ញាធរមិនដែលរករឿង និងសួរនាំពីការស្នាក់នៅសោះឡើយ ។

លោក ស្រ៊ុន ម៉េងហ៊ាង បន្តថា ពួកយួនគេហាក់ដូចជាមានអំណាច និងមានការយកចិត្តទុកដាក់ពីអាជ្ញាធរទៀតផង ដូចជាពួកនិគមយួននៅតាមតំបន់ឆ្នុកទ្រូមានទាំងបង្កើតសមាគមជាភូមិក្រុម និងមិនអនុញ្ញាតឱ្យខ្មែរយើងទៅរកត្រីក្នុងតំបន់ដែលពួកវារស់នៅនោះទេ ។ ជាញឹកញាប់ពលរដ្ឋខ្មែរដែលទៅរកត្រីសាច់ត្រូវពួកយួនជេរប្រមាថ និងវាយដំក៏មាន ដែរ ។

អ្នកស្រី ង្វៀង ធីឌីក ដែលកំពុងរុញរទេះដើរទិញអេតចាយបានឱ្យដឹងថា គ្រួសារគាត់មករស់នៅស្រុកខ្មែរ តាំងពីក្រោយរំដោះ 7 មករា 1979 ម្ល៉េះ ដែលកាលណោះគាត់រស់នៅជាយដែន ហើយនាំគ្នាមកស្រុកខ្មែរ ពីព្រោះវាងាយស្រួលរកស៊ីមិនដូចស្រុកយួនទេ ។

ង្វៀង ធីឌីក បន្តថា រហូតមក ដល់ពេលនេះកូនចៅគាត់រៀនអក្សរខ្មែរបានថ្នាក់ខ្ពស់ និងចេញធ្វើការជាមួយខ្មែរខ្លះហើយ ។ ចំណែកអ្នកខ្លះទៀតគេមានមុខរបរគ្រាន់បើក្លាយជាអ្នកមានរស់នៅជាមួយភូមិខ្មែរបានយ៉ាងសុខសាន្តទៀតផង ។

ង្វៀង ធីឌីក បញ្ជាក់ថា ពួកជនជាតិយើងខ្លះមានអត្តសញ្ញាប័ណ្ណ ខ្លះមានប័ណ្ណគ្រួសារ ហើយអ្នកខ្លះទៀតក៏គ្មានតែពុំសូវមានអ្នករករឿងទេ ។ ប៉ុន្តែចង់ធ្វើប័ណ្ណអ្វីក៏ដោយ គឺអាជ្ញាធរមិនដែលរារាំងនោះទេ គ្រាន់តែចំណាយលុយប្រមាណ 20ដុល្លារជាការស្រេច ។

ទាក់ទងទៅនឹងនិគមយួនខុសច្បាប់នេះ បើតាមឯកសាររបស់គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបង្ហាញឱ្យឃើញថា មានពួកយួនដែលចូលមករស់នៅលើទឹកដីកម្ពុជាខុសច្បាប់ជាង2លាននាក់ ហើយអ្នកខ្លះបានប្តូរឈ្មោះ និងត្រកូលធ្វើជាខ្មែរទៀតផង ។

ប្រភពខាងលើបញ្ជាក់ថា ជនអន្តោប្រវេសន៍ខុសច្បាប់ទាំងនេះ បានគាំទ្រពីគណបក្សប្រជា-ជនកម្ពុជា ក្នុងការបោះឆ្នោតទាំងថ្នាក់ ឃុំ-សង្កាត់ និងថ្នាក់ជាតិ ដែលក្នុងនោះពួកគេថែមទាំងមិនចេះនិយាយភាសាខ្មែរផង ។ ការដែលពួកគេធ្វើដូច្នេះបាន ក៏ដោយសារតែមេភូមិចេញទំរង់ 1018 បោះឱ្យឈ្មោះខ្មោច ដើម្បីឱ្យគណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោត ។ ជាភស្តុតាងឈ្មោះនិគមយួនទាំងនេះត្រូវបានគេស្រាវជ្រាវឃើញជាបន្តបន្ទាប់ និងបានប្តឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសហគមន៍អន្តរជាតិ ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានធ្វើការប្រឆាំងចំពោះនិគមយួនខុសច្បាប់យ៉ាងខ្លាំងក្លាហើយលោកក៏បានស្នើទៅរដ្ឋសភាឱ្យធ្វើច្បាប់ដើម្បីប្រឆាំងនឹងបញ្ហានេះ ប៉ុន្តែរហូតមកដល់ពេលនេះច្បាប់នេះពុំទាន់ចេញរួចនៅឡើយទេ ។

លោក សម រង្ស៊ី ធ្លាប់បានហៅសភាដែលជាប់ឆ្នោតថ្មីអាណត្តិទី4នេះថា ជាសភាខ្មោចសភាយួន ពីព្រោះមានជនជាតិយួនគាំទ្របោះឆ្នោតឱ្យ និងរកឃើញឈ្មោះយួនដែលបន្លំសន្លឹកឆ្នោតនៅតាមស្ថានីយមួយចំនួនរាប់ពាន់នាក់ទៀតផង ។

គួរបញ្ជាក់ថា តាមរដ្ឋធម្មនុញ្ញជនបរទេសដែលមករស់នៅលើទឹកដីកម្ពុជា ត្រូវតែមានឡាយព្រះហស្តពីព្រះមហាក្សត្រ ទើបចូលជាពលរដ្ឋពេញសិទ្ធិ ប៉ុន្តែបើតាមការសង្កេតស្រុកខ្មែរ គឺធ្វើត្រឹមតែរដ្ឋមន្ត្រីប៉ូលិសសង្កាត់ និងខណ្ឌប៉ុណ្ណោះ ។

ការកើនឡើងនៃអន្តោប្រវេសន៍យួននេះ ក៏បណ្តាលមកពី ហ៊ុន សែន នាយករដ្ឋមន្ត្រីបច្ចុប្បន្នធ្លាប់ពឹងពាក់យួន និងយួនលើកបន្ទុកតាំងពីមុនមក ទើបមិនហ៊ានថានឹងចេះតែបណ្តែតបណ្តោយ និងបង្កលក្ខណៈឱ្យថែមទៀត ។

ស្ទើរគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា ពួកយួនបានតាំងទីលំនៅខុសច្បាប់ និងប្រកបមុខរបរធម្មតាកាន់តែច្រើន ដែលជាក្តីបារម្ភមួយរបស់កម្ពុជា ហើយបានអនុវត្តយុទ្ធសាស្ត្រច្រេះស៊ីដែក តែអ្នកដឹកនាំខ្មែរមិនដែលឈឺក្បាលនោះទេ ៕



(តមកពីទំព័រទី០៨)

# រោងចក្របិទទ្វារកម្មករ...

បានត្អូញត្អែរថា រយៈពេល2ខែមកហើយ ថៅកែបើកលុយឱ្យមានការយឺតយ៉ាវខ្លាំងណាស់ ហើយបានសន្យាថា ចាំបុណ្យអុំទូកចប់នឹងបើកឱ្យ80% ប៉ុន្តែនៅពេលចប់ពិធីបុណ្យ ស្រាប់តែបើកឱ្យ80% ហើយមិនឃើញបើកឱ្យ20%ទៀត ទើបពួកគេមិនចូលធ្វើការ ។

សួង សុផាណា បន្តថា ពេលនេះកម្មករបាននាំគ្នាធ្វើកូដកម្មមិនព្រមចូលធ្វើការសុំបើកប្រាក់ខែឱ្យបានទៀងទាត់ និងគ្រប់ចំនួន ពីព្រោះកម្មករជួបការលំបាកផ្នែកជីវភាព និងត្រូវឱ្យថ្លៃឈ្នួលផ្ទះគេផង ។

លោក ខន សុជា កម្មករនៅរោងចក្រហ្គាមិនត្រេឌីងក្រុងភ្នំពេញ និយាយទាំងអស់សង្ឃឹមថា ពួកគាត់ធ្វើការរយៈពេលមួយខែ ហើយប៉ុន្តែថៅកែមិនឃើញបើកប្រាក់ខែឱ្យ ហើយពេលនេះស្រាប់តែរោងចក្រជូនដំណឹងថា ត្រូវផ្អាកមួយរយៈសិន ។ ដំណឹងនេះធ្វើឱ្យបងប្អូនកម្មករយើងនឹងជួបការលំបាកខ្លាំងណាស់ ពីព្រោះពួកយើងរកមួយថ្ងៃសំរាប់មួយថ្ងៃប៉ុណ្ណោះ ។

លោក ជា មុនី ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាបានឱ្យដឹងថា ការបិទទ្វាររោងចក្រ និងការព្យួរការងារបណ្តោះអាសន្ននៅតាមរោងចក្រមួយចំនួនក្នុងក្រុងភ្នំពេញនោះ វាបានជះឥទ្ធិពលកាន់តែអាក្រក់ទៅលើជីវភាពកម្មករ គឺធ្វើឱ្យពួកគាត់បាត់បង់ការងារ ហើយត្រូវបង្ខំចិត្តរកការងារផ្សេងធ្វើ ខ្លះទៀតក៏ត្រឡប់ទៅស្រុកកំណើតវិញ ។

លោកប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាបន្តថា នេះជាសញ្ញាអាក្រក់មួយសំរាប់កម្មករនៅទូទាំងប្រទេសដែលផ្ញើខ្លួនលើរោងចក្រដើម្បីរកលុយទៅដោះស្រាយជីវភាពក្រុមគ្រួសារឯស្រុកកំណើតនោះ ។ លើសពីនេះទៅទៀត វាក៏បានជះឥទ្ធិពលដល់ផ្នែកសេដ្ឋកិច្ចមួយផ្នែកទៀតផង ។


កម្មការិនីកំពុងធ្វើការនៅក្នុងរោងចក្រ

លោក វង សូត្រ រដ្ឋមន្ត្រីក្រសួងការងារបានឆ្លើយថា មួយរយៈចុងក្រោយបន្ទាប់ពីមានវិបត្តិសេដ្ឋកិច្ចនៅលើទីផ្សារពិភពលោកមានរោងចក្រតូចធំប្រមាណជាង10បានបិទទ្វារ និងរោងចក្រខ្លះទៀតបានផ្អាកការបញ្ជាទិញ ដោយសារក្រុមហ៊ុនជាដៃគូនៅអាមេរិក សហភាពអឺរ៉ុប ហើយបើទិញ គឺក្នុងតំលៃថោកដែរ ។

លោករដ្ឋមន្ត្រីក៏បានបន្តថា ទង្វើនេះបានបង្ខំចិត្តឱ្យថៅកែមួយចំនួនត្រូវផ្អាកការងាររកស៊ីរបស់ខ្លួនមួយរយៈសិន ទំរាំសេដ្ឋកិច្ចនៅអាមេរិកមានដំណើរការល្អវិញ ។ មិនយូរមិនឆាប់សេដ្ឋកិច្ចពិភពលោកនឹងប្រសើរឡើងវិញ ហើយវិស័យកាត់ដេរក៏ដូចគ្នាដែរ ។

ជាមួយគ្នានេះដែរ សមាគមសេដ្ឋកិច្ចកម្ពុជាបានធ្វើសន្និសីទកាសែតបង្ហាញពីការធ្លាក់ចុះនៃប្រាក់ចំណូលពីវិស័យកាត់ដេរនៅពេលខាងមុខយ៉ាងធ្ងន់ធ្ងរ ។ តាមតួលេខរបស់ក្រសួងពាណិជ្ជកម្មបានបង្ហាញថា វិស័យកាត់ដេរផ្តល់ប្រាក់ចំណូល4.6% ក្នុងរយៈពេល10ខែដំបូងនៅឆ្នាំនេះ ។

ក្នុងរយៈពេល10ខែដូចគ្នានេះ ប្រាក់ចំណេញបានធ្លាក់ចុះពី 39% ក្នុងឆ្នាំ2006 និង 15.5% ឆ្នាំ2007 មកនៅត្រឹម2.5%ក្នុងឆ្នាំ2008នេះ ។

លោក កង ចាន់តារ៉ាវ័ត្ថ នាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ដើម្បីការសិក្សាអភិវឌ្ឍន៍បានបញ្ជាក់ក្នុងសន្និសីទកាសែតថា ប្រាក់ចំណូលបានធ្លាក់ចុះ ហើយការធ្លាក់ចុះនេះបានបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង និងប៉ះពាល់ដល់វិស័យកាត់ដេរនៅកម្ពុជា ដែលកើតមានយ៉ាងច្បាស់ ។

លោក កង ចាន់តារ៉ាវ័ត្ថ បន្តថា ឥឡូវនេះការងារក្នុងវិស័យកាត់ដេរកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដែលជាចំណុចសំខាន់របស់សេដ្ឋកិច្ចជាតិ ។ បញ្ហានេះបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុសាកលលោកដែលកំពុងតែប៉ះពាល់ដល់ឧស្សាហកម្មកាត់ដេរ ត្រូវដកការនាំចេញហៀបនឹងកើតមាន ចំណែកឯសហភាពអឺរ៉ុបក៏ដកការនាំចេញដែរ ។

លោកនាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាដើម្បីការសិក្សាអភិវឌ្ឍន៍ បានបញ្ជាក់ថា "ពេលនេះអំណាចបញ្ជាទិញធ្លាក់ចុះនៅអាមេរិក ដោយសារតែវិបត្តិហិរញ្ញវត្ថុ និងផលប៉ះពាល់ជាច្រើនទៀត ។ ជាមួយគ្នានេះដែរ លោក ជាតិ ខេមរា អ្នកសម្របសម្រួលកូដកម្មនៅសមាគមរោងចក្រកាត់ដេរកម្ពុជា បានឱ្យដឹងថា សញ្ញានៃការធ្លាក់ចុះ និងបិទទ្វាររោងចក្រមាន20ទៀតដែលនឹងត្រូវផ្អាក ហើយកម្មករភាគច្រើនត្រូវបាត់បង់ការងារធ្វើ ។

លោក ជាតិ ខេមរា បន្តថា រហូតមកដល់ពេលនេះ កម្មករប្រមាណជាង62,000នាក់ បានបាត់បង់ការងាររបស់ខ្លួន ខណៈពេលដែលមនុស្សជាង4សែននាក់ កំពុងស្វែងរកការងារធ្វើនោះ ។ ពេលនេះបាតុកម្មក៏កើតមានជាហូរហែ ដែលធ្វើឱ្យអ្នកវិនិយោគិនមានការព្រួយបារម្ភកាន់តែខ្លាំងទ្បើង និងឈានទៅបោះបង់ការងារនេះទៀតផង ។

ក្នុងមួយឆ្នាំៗចំណូលបានបាត់ក្នុងវិស័យកាត់ដេរ មានប្រមាណ70លានដុល្លារ ដោយសារតែការិយាល័យធិបតេយ្យ និងអំពើពុករលួយរបស់អ្នកដឹកនាំមួយចំនួន ហើយក្រសួងពាណិជ្ជកម្ម និងការងារហាក់ដូចជាមិនសូវចាប់អារម្មណ៍ទៀត ៕


## ចង់ចេញពីភាពទ្រុឌទ្រោម? RELIV អាចប្តូររូបរាងកាយឱ្យមាំទាំបាន


Dr. Earleen Ong, Fellow of Geriatric Medicine, Certified Family Physician
Dr. John Harold Ong, Orthomolecular Medicine, Associate of Geriatric Medicine

**Reliv: Nutrition for the 21st Century**

Today's modern processing techniques rob essential nutrients from much of our food. Reliv restores the balance by delivering a unique blend of the vitamins, antioxidants, minerals, proteins, amino acids and phytonutrients the body needs to restore energy, fight off infections and feel great — every day.




- ពិសារ Reliv រាល់ថ្ងៃ គឺនាំឱ្យមានកម្លាំងកាយ រូបរាងមាំមួន សម្ផស្សស្រស់បស់ឡើងបាន
- Reliv អាចទប់ស្កាត់នូវជំងឺមួយចំនួនធំ ដែលកើតមកពីការពិសារចំណីអាហារខ្វះជីវជាតិ ធ្វើឱ្យសរីរាង្គគាំងដំណើរ
- ពិសារ Reliv លោក-អ្នកនឹងដឹងពីប្រសិទ្ធភាព ចាប់តាំងពីថ្ងៃដំបូង ដែលលោក-អ្នកប្រើ Reliv នេះភ្លាម ។

សូមទូរស័ព្ទជាវនៅលេខ : (636) 537 9715
. ដោយផ្តល់លេខសំគាល់ : RNC .7070 438001
បញ្ជាទិញ 1. RELIV CLAASIC មួយកំប៉ុង
2. Reliv INNERGINE មួយកំប៉ុង ដែលជាចំណីជីវជាតិ
លាយ RELIV 1 និង RELIV 2 ម្ខាងមួយស្លាបព្រាក្នុងទឹកផ្លែឈើហើយពិសារម្តង ឬពីរដងក្នុងមួយថ្ងៃ ទៅតាមភាពទ្រុឌទ្រោមនៃរូបរាងកាយ
" ភាពរឹងមាំកើតឡើងស្ទើរជឿមិនបាន "

ម្យ៉ាងវិញទៀត : នៅពេលឃើញប្រសិទ្ធភាពនៃ Reliv លោកអ្នកនឹងមានជំនឿថាអាចចែកចាយឱ្យមនុស្សច្រើនទៀតបាន

សូមទាក់ទងមកយើងខ្ញុំ ដើម្បីចុះឈ្មោះជា RELIV DISTRIBUTOR បន្តទៅទៀត លោកអ្នកអាចនឹងចំណេញប្រាក់ច្រើន ដោយសារតែបានជួយអ្នកដទៃឱ្យមានសុខភាពល្អដូចលោកអ្នកបាន
ទូរស័ព្ទនៅ Philadelphia : (267) 254 8758 នៅ VIRGINIA 703 415- 6257

WWW.RELIV.COM

(តមកពីទំព័រទី...)

# ស៊ូស្លាប់ខ្លួន កុំឱ្យស្លាប់ជាតិ

ដើម្បីឱ្យបានដឹងពីគំនិត និងផែនការរបស់ចោរ ហើយចោរនេះ ពុំមែនជាចោរធម្មតាទេ គឺចោរប្លន់ប្រទេសជាតិដទៃយកមកធ្វើជាប្រទេសជាតិរបស់ខ្លួន ដូច្នេះបុគ្គលណា ដែលនៅតែរួមចិត្ត រួមដៃ រួមកាយជាមួយចោរ ដោយសារតែចោរបានលើកតំកើង តែងតាំងឱ្យមានអំណាច លុយកាក់ និងទ្រព្យសម្បត្តិមហាសាល រួចហើយប្រព្រឹត្តអំពើព្រៃផ្សៃឃោឃៅ កាប់សម្លាប់ ចាប់ដាក់ គុកជនរបស់ខ្លួនឯង បុគ្គលទាំងអស់នេះ ពិតប្រាកដណាស់ ពុំបានទុកខ្លួនជាជនជាតិខ្មែរពិតប្រាកដទេ ។

ទង្វើ និងការប្រព្រឹត្ត និងសេចក្តីប្តេជ្ញាចិត្ត ហ៊ានលុះបង់គ្រប់បែបយ៉ាង សូម្បីតែជីវិតក៏ហ៊ានលះបង់ដែរ របស់លោក ប៉ែន សុវណ្ណ នេះ ត្រូវតែជនជាតិខ្មែរគ្រប់មជ្ឈដ្ឋានទាំងអស់ប្រមូលសតិបញ្ញា វិចារណញ្ញាណ សតិសម្បជញ្ញៈ មកធ្វើការវិភាគ វិចារណា ដើម្បីជ្រើសរើសយកមកតំកល់ទុកនៅក្នុងក្រអៅបេះដូង និងខួរក្បាល ដែលចាត់ទុកជាពន្លឺមួយដ៏ភ្លឺថែងចាំង បញ្ជាំងឱ្យឃើញ យ៉ាងច្បាស់នូវរតនៈវត្ថុដ៏វិសេស ដែលគេបានលាក់ទុកនៅក្នុងទីយ៉ាងងងឹតសូន្យសុង អស់រយៈពេលរាប់រយឆ្នាំមកហើយ ។

នៅពេលបានឃើញ ហើយដឹងយ៉ាងច្បាស់ ដូច្នេះហើយជនជាតិខ្មែរទាំងអស់ត្រូវតែរួមសាមគ្គីគ្នាឱ្យបានជិតស្និតនិងជំហរយ៉ាងរឹងមាំបំផុត ឈរនៅលើគោលការណ៍លទ្ធិប្រជាធិបតេយ្យពិតប្រាកដជាមួយសកម្មជន បញ្ញាវន្ត និងប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ ដែលមានឆន្ទៈអង់អាចក្លាហានហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ក្នុងបុព្វហេតុជួយសង្គ្រោះស្រោចស្រង់ប្រទេសជាតិ មាតុភូមិ ពូជសាសន៍ខ្មែរ ឱ្យបានរំដោះចេញផុតពីផែនការរបស់អាណានិគមយួន រួចហើយទ្រទ្រង់ ថែរក្សា ការពារឱ្យបានគង់វង្ស ស្ថិតស្ថេរចេរកាលជារៀងរហូតទៅ ។

ដោយត្រូវយកតាមវិភាពនៃលោក ប៉ែន សុវណ្ណ ដែលគាត់បានថ្លែងប្រាប់អ្នកសារព័ត៌មានសិទ្ធិសេរីភាពអំពីរូបគាត់ត្រូវលោក ហ៊ុន សែន ធ្វើតាមបញ្ជាយួន ទៅចាប់គាត់យកទៅដាក់គុកងងឹតនៅហាណូយ អស់រយៈពេលជាង១០ឆ្នាំ ដោយសារតែគាត់ប្រឆាំងនឹងយួន និងស្នើសុំឱ្យយួនគោរពអធិបតេយ្យភាពជាតិរបស់ខ្មែរ នៅលើចំណុចពីរ គឺ :

- ទី១ : សុំឱ្យយួនដកកងទ័ពចេញពីប្រទេសខ្មែរ ។
- ទី២ : លោក ប៉ែន សុវណ្ណ មិនព្រមឱ្យយួនអនុវត្តន៍ផែនការយុទ្ធនាការ **ក៥** ដែលជាផែនការយួនចង់សម្លាប់ជីវិតជនជាតិខ្មែរ និងបំផ្លេចបំផ្លាញព្រៃឈើខ្មែរតាមរយៈយុទ្ធនាការ **ក៥** នោះ ។ ជាពិសេស លោក ប៉ែន សុវណ្ណ បានថ្លែងពីអាថិកំបាំងនៃផែនការយួនជាច្រើន ឱ្យជនរួមជាតិខ្មែរ បានដឹងយ៉ាងច្បាស់សំរាប់ជាជំនួយដល់សតិស្មារតីរបស់កុលបុត្រ កុលធីតាខ្មែរទាំងអស់ឱ្យបានដឹង ហើយរួបរួមសាមគ្គីគ្នាជាធ្លុងមួយ ធ្វើការតវ៉ាទាមទារប្រើប្រាស់សិទ្ធិសេរីភាពជាជនជាតិខ្មែរម្ចាស់ស្រុក ក្នុងគតិយុត្តិធម៌សន្តិវិធី និងអហឹង្សា នៅក្នុងគោលការណ៍ប្រជាធិបតេយ្យពិតប្រាកដ ។

ទោះបីសព្វថ្ងៃប្រទេសខ្មែរ មានសន្តិភាពមែន ប៉ុន្តែជាសន្តិភាពបានមកដោយសារតែយួនបានសម្រេចជោគជ័យជាស្ថាពរនៅលើប្រទេស និងជនជាតិខ្មែរ ។ រីឯការរីកចំរើនគ្រប់វិស័យ ហេដ្ឋារចនាសម្ព័ន្ធ ក៏ដោយសារលុយជាជំនួយនិងប្រាក់ខ្ចីរាប់ពាន់លានឆ្នាំពីប្រទេសនានា ដែលជាជំនួយខ្លះប្រកបដោយសុទ្ធចិត្ត និងជំនួយខ្លះបានបង្កនូវពិសពុលធ្វើឱ្យជនជាតិខ្មែរ មានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំងអំពីការរលំរលាយ បាត់បង់ទៅនៃប្រទេស និងជនជាតិ ពូជសាសន៍ខ្មែរទៅអនាគតដ៏ខ្លីខាងមុខនេះ ដូចជាផែនការសម្ងាត់របស់យួន ដែលលោក ប៉ែន សុវណ្ណ បានថ្លែងឱ្យដឹង និងតាមការកត់ត្រាទុកនៃប្រវត្តិសាស្ត្រខ្មែរ នោះជាភស្តុតាងស្រាប់ ជាពិតប្រាកដផងដែរ ៕


# The Khmer Post

Cambodian American Biweekly Newspaper

**PRINT AND INSERT**

*We're Keeping our insert costs low and best of all, we do all the for you !*

**We collaborate with your ideas and Information to design, print and mail a great, guality insert.**

**With our insert program, you can pick the zip code combination that works for you . Target your specific market area, and see your insert delivered to every single home in those zip codes !**

**For more information, call (267) 253-3947**





ទំព័រវិធីបំភ្លឺជីវិត

# ពេលវេលាជាគុណភាពនៃជីវិត

**ចងក្រង និងប្រែសំរួលដោយ អ៊ុម លឿម**

❖❖❖"ពេលវេលា" ជាវត្ថុអរូបិយ៍ ដែលយើងមិនអាចមើលនឹងភ្នែកទទេបានឡើង ។ ក៏ប៉ុន្តែផ្ទុយទៅវិញ វត្ថុអរូបិយ៍មួយនេះ បែរជាមានតម្លៃដ៏សែនខ្ពស់មហាសាល និងពុំអាចរកវត្ថុមានតម្លៃអ្វីមកប្រៀបផ្ទឹមបានទេ ទោះបីជាពេជ្រពិទូរ្យសូរ្យកាន្ត ក៏ពុំអាចមានតម្លៃស្មើនឹងពេលវេលាបានឡើយ ។

សម្រាប់អ្នកដែលទទួលបាននូវក្តីសម្រេចជោគជ័យក្នុងខ្សែជីវិត អ្នកនោះរមែងតែងតែព្យាយាមធ្វើនូវអ្វីមួយ ក្នុងមួយថ្ងៃៗឱ្យបានកើតជាប្រយោជន៍ដល់ខ្លួនឯង ដោយពុំបានបណ្តែតបណ្តោយឱ្យពេលវេលាកន្លងផុតទៅដោយគ្មានតម្លៃ ឬឥតប្រយោជន៍ឡើយ ។ យើងត្រូវដឹងថាពេលវេលា ដែលកន្លងផុតទៅមុនហើយ ពិតជាពុំអាចវិលត្រឡប់ថយក្រោយវិញបានឡើយ សមដូចចម្រៀងថ្នាក់កុមារដ្ឋានមួយរបស់ បានរៀបរាប់ថា " មើលពេលាវេលា ដែលកន្លងផុតទៅ គ្មានពេលណានៅហ្នឹងថ្កល់ឈរឈប់ អណ្តែតត្រសែតគ្មានពេលត្រឡប់មកប្រញាប់ទាន់ខ្លួននៅក្មេងៗ" ។

ដោយហេតុនេះ ដើម្បីធ្វើនៅអ្វីមួយឱ្យចេញជាប្រយោជន៍ចំពោះខ្លួនឯង និងមានបរិមាណខ្ពស់បំផុតគួរអនុវត្តនូវរូបមន្តទាំង ៦ចំណុចខាងក្រោមនេះ :

១. ប្រើប្រាស់ពេលវេលាជាមួយមិត្តភ័ក្រ្ត និងសង្គម ព្រោះទាំងអស់នេះ អាចជួយយើងឱ្យមានសេចក្តីសុខ, ជួយបន្ធូរបន្ថយនូវភាពធុញថប់ តប់ប្រមល់ និងអាចចងក្រងឱ្យកើតជាសម្ព័ន្ធដ៏ល្អខាងផ្លូវអាជីវកម្ម ឬការងារល្អក្នុងថ្ងៃអនាគត ខាងមុខ ។

២. ប្រើប្រាស់ពេលវេលាជាមួយការធ្វើការដោយការចាប់អារម្មណ៍ ឬយកចិត្តទុកដាក់បំផុតដោយមិនត្រូវគិតថា ការងារក្នុងមួយថ្ងៃមានចំនួនប្រាំបីម៉ោង ឬដប់ពីរម៉ោងថា ជាពេលវេលាដ៏សែនយូរពេកឡើយ ។

៣. ប្រើប្រាស់ពេលវេលា ដើម្បីស្វែងរកបទពិសោធន៍ និងចំណេះដឹងថ្មីបន្ថែមទៀត ព្រោះអីជីវិតដែលពុំមានសិក្សា គឺជាជីវិតដែលបាត់បង់នូវឱកាសដ៏មានសារៈប្រយោជន៍ ។

៤. ប្រើប្រាស់ពេលវេលាជាមួយក្រុមគ្រួសារ ដើម្បីផ្តល់នូវក្តីស្រឡាញ់, ផ្តល់នូវភាពកក់ក្តៅ ព្រោះទាំងនេះហើយ វាជាកម្លាំងចិត្តដ៏ចម្បងបំផុត ។

៥. ប្រើប្រាស់ពេលវេលាសំរាប់ឈប់សំរាក និងហាត់ប្រាណ ដើម្បីឱ្យរាងកាយមានភាពរឹងប៉ឹងមាំមួន ឬក៏អាចស៊ូជាមួយនឹងកិច្ចការ ឬបញ្ហាផ្សេងៗដែលអាចកើតឡើងជាយថាហេតុបានយ៉ាងល្អ ។

៦. ប្រើប្រាស់ពេលវេលាសំរាប់ខ្លួនឯងផ្ទាល់, ធ្វើនូវអ្វីដែលខ្លួនយើងពេញចិត្តចង់ធ្វើ ។ ជាកត្តារួមយើងអាចនិយាយបានថា " ពេលវេលា " មានតម្លៃដ៏មហាសាលសំរាប់អ្នកដែលត្រូវការនូវភាពសម្រេចជោគជ័យដូចទ្រឹស្តីរបស់វាគ្មិនទស្សនៈវិទូបច្ចឹមប្រទេសមួយរូប បានពោលថា " ចូលកុំបិទទ្វារឃ្លាំងទាំងខ្លួនឯងស្ថិតនៅក្នុងពិភពដ៏សែនតូចចង្អៀតឱ្យសោះ... នៅពិភពខាងក្រៅមានវត្ថុប្លែកៗ និងវត្ថុថ្មីៗជាច្រើនទៀត ហើយវត្ថុប្លែកៗ និងថ្មីៗទាំងនោះ យើងប្រើពេលវេលា ដើម្បីស្វែងយល់អស់មួយជីវិតក៏នៅពុំចេះចប់ ពុំចេះសព្វដែរ " ៕

**" កុំភ្លេចអនាគត កុំរន្ធត់អតីតកាល "**




# បណ្ណបញ្ជាកាសែតខ្មែរប៉ុស្តិ៍

ខ្ញុំចង់ឱ្យ " ខ្មែរប៉ុស្តិ៍ " ផ្ញើរកាសែតជាភាសាខ្មែរ ដែលសំបូរដោយព័ត៌មានក្នុងសហគមន៍ខ្មែរនៅបរទេស មកឱ្យខ្ញុំជាប្រចាំ រៀងរាល់ពេល ដែលកាសែតនេះចេញផ្សាយ មួយខែពីរដង ។

ឈ្មោះ និងអាស័យដ្ឋានរបស់ខ្ញុំ :

ឈ្មោះ :..........................................................

អាស័យដ្ឋាន :..................................................

..........................................................U.S.A.

ទូរស័ព្ទ :........................................................

អ៊ីមែល :.........................................................

ខ្ញុំផ្ញើរភ្ជាប់ជាមួយនូវ សែក ឬ មានីអដ័រ មក U.A.M.G ចំនួនមួយខែតម្លៃ ៥ ដុល្លារ ×........( ចំនួនមួយខែ ) =...................

U.A.M.G 5730 Rising Sun Avenue Philadelphia,PA 19120

**Phone / Fax : (215) 722-2226**

## (តមកពីទំព័រទី០៧) កម្ពុជាគ្មានព្រំដែនត្រួតស៊ីគ្នានៅ...

ហើយយកបណ្តឹង ទៅអន្តរជាតិជួយដោះស្រាយ ដែលជាជំរើសដ៏ល្អបំផុតសំរាប់ប្រទេសយើង ។

លោក ផៃ ស៊ីផាន រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី បានឱ្យដឹងថា ទោះបីជាការចរចាមិនទទួលបានផ្លែផ្កាយ៉ាងណាក៏ដោយរដ្ឋាភិបាលនៅតែប្រកាន់ជំហរចរចាទ្វេភាគីដដែល ហើយយើងព្យាយាមប្រើប្រាស់ឱ្យអស់លទ្ធភាពរបស់យើង ។ កន្លងមកយើងមានគណៈកម្មាធិការព្រំដែនកម្ពុជា-សៀមក្នុងការពិនិត្យបង្គោលព្រំដែនគោកចំរុះ ការបោះខណ្ឌសីមា និងបានឯកភាពគ្នាបញ្ចប់ទំនាស់នៅប្រាសាទព្រះវិហារស្តីពីការប្រើប្រាស់ផែនទី ឬក៏ការប្រើប្រាស់ដីធ្លីដណ្តើមគ្នានោះ ។ លោក ផៃ ស៊ីផាន បន្តថា បញ្ហានេះយើងពុំបានចរចាអ្វីទេ ពីព្រោះយើងមានផែនទីដែល មានអាយុ100ឆ្នាំរួចមកហើយ គឺយើងគ្រាន់តែសំរបសំរួលគ្នាផ្នែកបច្ចេកទេសប៉ុណ្ណោះ ។

លោក សុន ឆ័យ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានបញ្ជាក់ដដែលថា ទំនាស់ព្រំដែនកម្ពុជា-សៀមនេះ យើងមានឯកសារគ្រប់គ្រាន់ដើម្បីប្តឹងទៅសហគមន៍អន្តរជាតិជួយដោះស្រាយតាមផ្លូវច្បាប់ គឺយើងមិនត្រូវចរចាទ្វេភាគីទេ ពីព្រោះពួកសៀមមានលេសច្រើន ហើយមានប្រៀបជាងកម្ពុជាទៀតផង ។

លោក សុន ឆ័យ បន្តថា លោកគ្មានជំនឿថា ការចរចាទ្វេភាគីនេះទទួលបានផ្លែផ្កានោះទេ គឺបានត្រឹមតែខាតពេលវេលាឥតប្រយោជន៍ ហើយពួកសៀមឆ្លៀតឱកាសកេងចំណេញពីយើងទៀត ។ ដូចករណីនេះសៀមថា មានផែនទីត្រួតស៊ីគ្នា4.6គីឡូម៉ែត្រ នៅចំណុចប្រាសាទដល់អន្តរជាតិទៀត ។

ចំណែកលោក ស៊ាន ប៉េងសែ ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំងក៏បានបញ្ជាក់ថា តាមរយៈសាលក្រមរបស់តុលាការអន្តរជាតិទីក្រុងឡាអេ ថ្ងៃទី15 ខែមិថុនា 1962 បញ្ជាក់យ៉ាងច្បាស់ថា កម្ពុជាគ្មានផែនទីត្រួតស៊ីគ្នាជាមួយសៀមទេ គឺប្រាសាទព្រះវិហារ និងបរិវេណ4.6គីឡូម៉ែត្រនោះ ជារបស់កម្ពុជាប៉ុណ្ណោះ ។

លោក ស៊ាន ប៉េងសែ ក៏បានជំទាស់នឹងការចរចាភាគីរវាងកម្ពុជា-សៀម គឺគ្មានបានផលអ្វីសោះឡើយ ពីព្រោះចាប់តាំង ចរចារយៈពេលជាច្រើនខែមកនេះ សៀមបានពន្យារពេលជានិច្ចរហូតដល់បញ្ជូនរឿងរ៉ាវជំលោះព្រំដែនឱ្យសភាគេយល់ព្រមទៀត ។

លោកបញ្ជាក់ថា ការចុះហត្ថលេខារឿងព្រំដែននៅឆ្នាំ2000 រវាង ហ៊ុន សែន និងថាក់ស៊ីន ស៊ីណាវ៉ាត្រា អតីតនាយករដ្ឋមន្ត្រីសៀមនោះ ខ្មែរយើងគ្មានចំណេញអ្វីទេ ហើយបង្កឱ្យមានរឿងរហូតដល់សព្វថ្ងៃនេះ ។

ប្រជាពលរដ្ឋទាំងក្នុង និងក្រៅប្រទេសនៅតែទទូចម្តងហើយម្តងទៀត សុំឱ្យ ហ៊ុន សែន បញ្ចប់ការចរចារឿងជម្លោះព្រំដែននេះ ហើយបញ្ជូនសំនុំរឿងឱ្យអង្គការសហប្រជាជាតិឱ្យបានឆាប់ បើពុំនោះទេ នឹងជាប់អន្ទាក់បាត់បង់ទឹកដីជាក់ជាពុំខានឡើយ ៕

## (តមកពីទំព័រទី០៩) វិបត្តិសេដ្ឋកិច្ចពិភពលោក...

ចំណែកកន្លែង ដែលគាត់បានទិញទុកយកចំណេញក៏ចុះថ្លៃប្រមាណ 20% ដែរ បញ្ហានេះ ធ្វើឱ្យគាត់ប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ ។

អ្នកស្រី សុន ចាន់ធី បន្តថា ទាំងដី និងផ្ទះដែលគាត់បានទិញទុកនោះ គឺគាត់ចងការលុយពីធនាគារមករកស៊ី ដល់ពេលវាគ្មានហាងឆេង ហើយធ្លាក់ថ្លៃបែបនេះ ធ្វើឱ្យគាត់ខាតទាំងការប្រាក់ និងលុយដែរទិញថែមទៀត ។ បើសិនជាវិបត្តិសេដ្ឋកិច្ចពិភពលោកនៅតែអូសបន្លាយបន្តទៀតនោះ គាត់នឹងត្រូវវិណ្ឌ.កមិនខានឡើយ ។

លោក មុត សេងលី អ្នកជំនាញសេដ្ឋកិច្ច បានឱ្យដឹងថា ផលប៉ះពាល់អវិជ្ជមាននោះនឹងមានពេលវែង ដរាបណាវិបត្តិសេដ្ឋកិច្ចមិនដោះស្រាយចេញ និងទំនាស់ព្រំដែនមិនទាន់បញ្ចប់នោះ ។ ដីធ្លី ផ្ទះសំបែង ដែលធ្លាប់តែមានម៉ូយដើរទិញនោះ ក៏មិនទាន់មានហាងឆេងដែរ ពីព្រោះសព្វថ្ងៃនេះ វាបានធ្លាក់ថ្លៃធ្ងន់ធ្ងរណាស់ សូម្បីសំណង់អាគារខ្ពស់ៗមួយចំនួនក៏ផ្អាកការសាងសង់ដែរ ។

ចំណែកវិស័យទេសចរណ៍ ដែលជាឧស្សាហកម្មគ្មានផ្សែង ហើយទាក់ទាញភ្ញៀវឱ្យមកទស្សនាប្រទេសកម្ពុជា នឹងផ្តល់ចំណូលរាប់ពាន់ដុល្លារក្នុងមួយឆ្នាំៗនោះ ក៏រងផលប៉ះពាល់ផងដែរ ។

លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ វិបត្តិសេដ្ឋកិច្ចពិភពលោក កំពុងតែបង្កការលំបាកយ៉ាងខ្លាំង ជាពិសេសប្រទេសសៀម ក៏បានជះឥទ្ធិពលមកដល់កម្ពុជាផងដែរ ពីព្រោះប្រទេសសៀម ជាច្រកចូលនៅភ្ញៀវទេសចរអន្តរជាតិដ៏សំខាន់មួយដែរ ។

លោក ថោង ខុន បន្តថា ទោះបីជាយ៉ាងយើងបាននឹងកំពុងតែប្រឹងប្រែងសហការជាមួយប្រទេសទាំងអស់លោកពិភពលោក ដើម្បីទាក់ទាញអ្នកទេសចរឱ្យបានកាន់តែច្រើន លោកមានសង្ឃឹមថា រយៈពេលដ៏ខ្លីខាងមុន ភ្ញៀវទេសចរនឹងកើនខ្ពស់គួរឱ្យកត់សំគាល់ ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានបញ្ជាក់ក្នុងសន្និសីទកាសែតថា វិបត្តិហិរញ្ញវត្ថុនៅលើពិភពលោក បានបង្កឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ, មន្ត្រីរាជការកាន់តែខ្លាំង ជាពិសេសវិស័យកាត់ដេរ, សំណង់អចលនៈទ្រព្យ, ដីធ្លី, វិស័យទេសចរណ៍ និងវិស័យមួយចំនួនទៀត


កសិដ្ឋានកំពុងសាងសង់នៅខេត្តបាត់ដំបង


ហាងលក់ដូរមិនសូវមានភ្ញៀវចូលទិញ ខណៈពេលមានវិបត្តិសេដ្ឋកិច្ច

ក្នុងប្រទេស គួរឱ្យបារម្ភខ្លាំងណាស់ ។

លោក សម រង្ស៊ី បានបញ្ជាក់ថា ប្រសិនបើរដ្ឋាភិបាល មិនដោះស្រាយឱ្យទាន់ពេលវេលាទេ កម្មករ, កសិករ, អាជីវករតូចតាច ប្រាកដជាជួបនឹងការលំបាកធ្ងន់ធ្ងរជាងគេ ហើយរោងចក្រសហគ្រាសនឹងបិទទ្វារកាន់តែច្រើន ហើយអត្រាអ្នកគ្មានការងារធ្វើនឹងកើនខ្ពស់គួរឱ្យបារម្ភ ៕


**Reasons Why You Want to Put**

The Advertisement on the Khmer Post
In Philadelphia

បុព្វហេតុដែលនាំឱ្យលោកអ្នកផ្សាយពាណិជ្ជកម្មនៅ "ខ្មែរប៉ុស្តិ៍"

The Khmer Post is the only Cambodian Newspaper that available to reach out over 30,000 Cambodian readers who live in Philadelphia.



"ខ្មែរប៉ុស្តិ៍" គឺជាប្រព័ន្ធផ្សព្វផ្សាយខ្មែរតែមួយ ដែលចែកផ្សាយដល់អ្នកអានខ្មែរប្រមាណ ៣ ម៉ឺននាក់ កំពុងរស់នៅហ្វីឡាដែលហ្វីយ៉ា

One phone call away to grow your business, 20% discount when you sign up for a of year contract by calling this number (267) 253-3947.

លេខទូរស័ព្ទដែលធ្វើឱ្យពាណិជ្ជកម្មលោកអ្នករីកដុះដាល គឺ :
**(267) 253-3947**
យើងខ្ញុំចុះថ្លៃជូន ២០ % បើលោកអ្នកផ្សាយ ១ ឆ្នាំ

**Growing your business. Advertise yourself.**


# Job Opportunity

## Socio-Economic Center for Southeast Asians (SEDC)

## Executive Director

**Dynamic, visionary, and culturally-competent Executive Director sought for the Socio-Economic Center for Southeast Asians (SEDC), a community-based nonprofit providing services to Rhode Island's Cambodian, Laotian, Hmong and Vietnamese communities. SEDC employs a family support model with services that include youth services, substance abuse prevention, family services, citizen and ESL classes, services for youth, and interpreting and translation services. The ideal candidate should have demonstrated success in participatory staff management, fundraising, fundraising, fiscal and contract management, and community engagement. Requirements: 5 years in progressive nonprofit management and experience working with Southeast Asian communities. Bi-lingual in one of the four community languages is a plus. Masters Degree preferred. Salary and benefits competitive.**

**For more information about position and job application process: www.sedcsea.org. Cover letter, resume, salary history and requirements, and 3 references (electronic submissions in MS Word only) to c/o Dr. Judy Freiwirth, Nonprofit Solutions Associates; Judy@NonprofitSA.com.**



# ហោរាសាស្ត្រប្រចាំខែ ធ្នូ ថ្ងៃទី ១៩-០៩



**ឆ្នាំជូត : (ពង្សទេវតាប្រុស ធាតុទឹក)**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹម១ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានផលចំណូលហូរចូលបានច្រើនក្រាស់ក្រែលគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញីក បើវព្ធកកុំទៅញួយ ទើបចំណង ស្នេហាអាចគង់វង្សបានយូរអង្វែង ៕



**ឆ្នាំឆ្លូវ : ( ពង្សមនុស្សប្រុស ធាតុដី )**

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការ-ងារអ្វីក៏ដោយ ក៏មានអ្នកជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ។ ចំពោះស្ត្រីភេទនៅលីវ និងត្រូវបានកម្លោះ១ចោមរោមស្រលាញ់ រហូតអាចឈានដល់ការស្តីដណ្តឹងយកធ្វើជាគូអនាគតទៀតផង ៕



**ឆ្នាំខាល : ( ពង្សយក្សស្រី ធាតុឈើ )**

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ឱកាសល្អ១បាន មកដល់ហើយ ដូច្នេះលោកអ្នកត្រូវតែរវៀសរវៃញាប់ជើងញាប់ដៃបន្តិច ព្រោះពេលវេលាជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈខែនេះ មានភាពស្និទ្ធស្នាលដូចប្រក្រតី ៕



**ឆ្នាំថោះ : ( ពង្សមនុស្សស្រី ធាតុឈើ )**

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ បើជាអាជីវករ អ្នករកស៊ីជួញដូរនឹងមានទំនិញលក់ចេញទិញចូលឥតទំនេរដៃ ព្រមទាំងមានទ្រព្យហូរចូលជាហូរហែទៀតផង ៕



**ឆ្នាំរោង : (ពង្សទេវតាប្រុស ធាតុមាស)**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹម១ ។ ក្នុងរយៈពេលនេះ បើជាបុគ្គលិកកម្មករដែលបំរើការងារនៅតាមក្រុមហ៊ុន ឬរោងចក្រនានា ចូរចេះដាក់ខ្លួនដាក់កាយ និងចេះធ្វើទំនាក់ទំនងល្អជាមួយនឹងចៅហ្វាយនាយ ឬថៅកែ ព្រមទាំងអ្នករួមការងារជាមួយ ទើបកិច្ចការងារអាចដំណើរការបានស្រួល ៕



**ឆ្នាំម្សាញ់ : (ពង្សមនុស្សប្រុស ធាតុភ្លើង)**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកអាចផ្អាករាល់កិច្ចការងារសំខាន់១មួយរយៈពេលសិន ព្រោះបើហ៊ានតែមានចិត្តមានះរឹងរូស គឺពិតជាស៊ីយធំអាចបង់ខាតទ្រព្យជាក់ជាមិនខាន។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែងតែម្នាក់ឯងឡើយ ប្រយ័ត្នបានជួបនឹងគ្រោះភ័យ ៕



**ឆ្នាំមមី : (ពង្សទេវតាស្រី ធាតុភ្លើង)**

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិត ប្រាជ្ញាឈ្លាសវៃ ទោះប្រកបកិច្ចការងារអ្វី១ក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់។ ចំពោះស្វាមីភរិយាវិញ មានភាពល្អូកល្អឺនគ្នាណាស់ ហើយពិសេស នោះស្រលាញ់គ្នាលើសមុនទៅទៀត ៕



**ឆ្នាំមមែ : (ពង្សទេវតាស្រី ធាតុមាស)**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាក១ច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឱ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីប្តូរប្រាក់ ឬលក់គ្រឿងអលង្ការមានតម្លៃផ្សេង១ ត្រូវប្រយ័ត្នប្រយែងមានជនខិលខូចលួចបន្លំ ឬឆក់ប្លន់ ៕



**ឆ្នាំវក : (ពង្សយក្សប្រុស ធាតុដែក)**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹម១ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសមុននឹងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃផ្សេង១ ចូរចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ព្រោះកាលបើមានការភ្លាំងភ្លាត់តែបន្តិច អាចបង់ខាតផលប្រយោជន៍ច្រើន ៕



**ឆ្នាំរកា : (ពង្សយក្សប្រុស ធាតុដែក)**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះប្រកែកកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់ ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ក្នុងរយៈពេលនេះ បើមានដំណើរទៅណាមកណា ចូរប្រយ័ត្នប្រ-យែងក្រែងជួបគ្រោះថ្នាក់ចរាចរ ៕



**ឆ្នាំច : ( ពង្សយក្សស្រី ធាតុដី )**

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះប្រកែកកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ក្នុងរយៈពេលនេះ បើមានដំណើរទៅណាមកណា ចូរប្រយ័ត្នប្រយែងក្រែងជួបគ្រោះថ្នាក់ចរាចរ ៕



**ឆ្នាំកុរ : (ពង្សមនុស្សស្រី ធាតុទឹក)**

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺនៅតែមានមនុស្សខិលខូចខ្លះប៉ងប៉ផ្លិចបំផ្លាញរាល់កិច្ចការងារ ដូច្នេះមុននឹងធ្វើអ្វីមួយ ឬមុននឹងធ្វើដំណើរទៅណាមកណា ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ មានការយល់ចិត្តគ្នាល្អ គ្មានបញ្ហាអ្វីកើតឡើងធំដុំទេ ៕


**Buy something... Sell something...Announce something...advertise on the Khmer Post Classifieds!**

**ប្រវត្តិសាស្ត្រនៃកម្ពុជា**

លោក វ៉ាន់ឌីការអុន ទើបនឹងសរសេរសៀវភៅប្រវត្តិសាស្ត្រនេះ ពីសម័យអាណានិគមបារាំង មកដល់បច្ចុប្បន្នកាល ។ ភាគទី1 បានសរសេចប់ចេញផ្សាយរួច ហើយនៅប្រទេសបារាំង ។ រីឯភាគទី2 នឹងចេញផ្សាយបន្តទៅទៀត នា-ពេលឆាប់១នេះ ។

រីឯប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្នមួយទៀត ជាថាសស៊ីឌី ដែលរៀបរៀងដោយ ពិន សំខុន ហើយផ្សព្វផ្សាយនៅវិទ្យុសម្លេងខ្មែរ-អាមេរិកាំង ។ ថាស ស៊ីឌី ចំនួនបួនម៉ោងស្តីពីប្រវត្តិកម្ពុជា ចាប់តាំងពីសម្តេចនរោត្តម សីហនុបានធ្លាក់ពីអំណាចនាឆ្នាំ 1975 មកដល់ ឆ្នាំ2004 ឆ្នាំដែលព្រះអង្គបានដាក់រាជសម្បត្តិថ្វាយព្រះរាជបុត្រារបស់ព្រះអង្គព្រះនាម នរោត្តម សីហមុនី ។

ស៊ីឌីនេះ មានលក់នៅខ្មែរប៉ុស្តិ៍ និងនៅវិទ្យុសម្លេងខ្មែរ- អាមេរិកាំង តម្លៃ $30 ។

សូមទូរស័ព្ទមកសុបិន **(267) 253 3947** ។

**Your Advertisement Is Here For Less than $10 for two weeks!**

**HAIR SALON FOR SALE**

Good Location in the Shopping, busy traffic area.
Red Lion and Verree Road.
18 years established.
Earn instance income
$68,000
2,000 sqt.
Call Tim @ 215-776-4174 for showings.

**លក់ $68.000**

➩ហាងកាត់សក់ អ៊ុតសក់ កំពុងដំណើរការណ៍ល្អ ។
➩ហាងស្ថិតនៅកន្លែងល្អ ក្នុងតំបន់ពាណិជ្ជកម្ម មានមនុស្សចេញចូលច្រើន ។
បើក 18ឆ្នាំហើយ មានទំហំ 2000Sqt ស្ថិតនៅជ្រុងផ្លូវ Red Lion និង Verree.
ហៅរក ធីម : (215) 776-4174 ដើម្បីបង្ហាញហាង ។

**Clip & Fax This Classified Coupon**

Classified Advertising
Name your category: Sales, Services, Fund Raisers…etc.
Our rates: $5.00 for up to 22 words
15 cents each additional words
Send us your ad in one of the following ways:
1. by Fax to (215) 722-2226
2-by mail to the Khmer Post 5730 Rising Sun Avenue. Philadelphia, Pa 19120
3-By phone (267) 253-3947
Payments methods: check or money order.
Name:................Address:..................
City:.........................State:..................
Zip:..............................................
Phone:..................Fax:......................
Your Advertisement Message:
..............................................
..............................................
..............................................

# វិធីសន្សំថាមពល

## ENERGY SAVING ACTION



#1 បើអ្នកប្រើកំដៅ. ចូរអ្នកបិទកន្លែងដែលបែកក្រហែង និងប្រហោងនៅជាន់ទីមួយសិន ។ អ្នកអាចបិទបិតគ្រប់ប្រហោងក្នុងគេហដ្ឋានរបស់អ្នកដោយចំណាយបន្តិចបន្តួច ឬក៏គ្មានចំណាយសោះ ។ វត្ថុដែលអ្នកប្រើប្រាស់មិនសំខាន់ស្មើនឹងកាយវិការ ដែលអ្នកធ្វើនោះទេ ។ ចូររក្សាខ្យល់ក្តៅឱ្យនៅក្នុងនេះ ពីរបៀបសន្សំប្រាក់កាស ។

#2 ញាត់ និងបិទជិតគ្រប់ប្រហោង និងក្រហែងដែលមានលេចចេញខ្យល់ក្តៅ
បើមានខ្យល់ត្រជាក់ជុំវិញបង្អួច ទ្វារ និងកន្លែងដទៃទៀត ដូចជា : នៅតាមពិដានយ៉រខាងមុខ និងកែមក្រោមបង្អួចឆក ។ ចូរអ្នកបិទគ្រប់ប្រហោងដើម្បីទុកខ្យល់ត្រជាក់ខាងក្នុងនោះ អ្នកនឹងមានសភាពស្រួលខ្លួន

#3 ចូរបិទកន្លែងដែលលេចនៅជាន់ក្រោមដី មានអ្នកខ្លះនិយាយថា ខ្លួនមិនបានចុះទៅជាន់ក្រោមទេ ។ បើសិនជាអ្នកមិនបិទប្រហោង ឬក្រហែងនោះទេ អ្នកនឹងគ្មានសំណាងបានសន្សំប្រាក់ នឹងបានក្តៅស្រួលទេ ។

Nationalities Service Center

---

# ( The Khmer Post Directory )

East Coast Publication
Regional Editor : Pin Samkhon
Email : pinsamkhon@gmail.com
Writers : Mam Yin
Kim Phean
Im Loeurm
Chhan Young
Advertising
Marketing/Advertising
Manager: Sabane Thach
Phone : 267-253-3947
Email : sabane.thach@gmail.com

West Coast Publication
RegionalEditor : Sovannara Meach
Writers : Kim Saroeurn
Ra Neat
Sophea Rith
Mey Sampos
Chan Kosal
Sovann Rith
Phone: (562) 313-2129
Email: sovannara04@yahoo.com


# APARTMENTS FOR SALE!
## Only $63,000



Location: 641 & 643 Mercy St. South Philly. Two bedroom, 1bathroom,1 living room and kitchen. 1 store front, and 1 garage. **please call Mr. Sebastian (Seb) Feeney for showings.**

**215-760-2101**

លក់ផ្ទះ (Apartment) : តម្លៃ $63.000/ ផ្ទះមួយ នៅហ្វីឡាខាងត្បូង ផ្ទះទីមួយៗមាន បន្ទប់ដេក២ បន្ទប់ទឹក ១ បន្ទប់ទទួលភ្ញៀវ និងផ្ទះបាយ ផ្ទះទី ១ មានហាងខាងមុខ ផ្ទះទី២ មានចំណតរថយន្ត (ពីមុខជាផ្សារលក់ត្រី)
លក់ដោយម្ចាស់ផ្ទះ សូមទូរស័ព្ទទៅ "សេបាសៀន" **(215) 760-2101**

# យព្រីក វីដេអូ
PKAY PREK VIDEO
(215) 455-2762
YORK RD. PHILADELPHIA, PA 19141





ជួលកុន_លក់ឌីវីឌី និង ស៊ីឌី
MOVIE RENTAL
DVD & CD SALES
CAMBODIAN FORMAL DRESSES
WOMEN & BABY CASUAL WEARS

# ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



## បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត

- Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ






*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

# ក្រុមហ៊ុន ទេសចរណ៍
## ...URY TRAVEL & SERVICE CENTER
...th 8th Street. Philadelphia, Pa 19147
... 215.625.2889 – Fax. 215.625.9395
...934.9888 – email: centuryphl@yahoo.com

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M

...កដោយគ្រប់ក្រុមហ៊ុន
...សំរាប់ដំណើរហើរ
...ក
...ផ្លូវជូនដំណើរ
...រ
...ដែនខ្មែរ
...ប្រវេសន៍
...ទេសចរណ៍
...ប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- National & International flights
- Khmer Passport Extension
- Immigration
- Tourist Visa
- Money Transfer
- Notary Public

... speak Khmer, Chinese Vietnamese
...យភាសាខ្មែរ_ភាសាចិន វៀតណាម

# NEW YORK LIFE
## អត់ពីលោកអ្នកទៅ តើបាននរណាជួយថែរក្សាកូនចៅលោកអ្នក ?

១-ទិញការធានារ៉ាប់រងសម្រាប់ជីវិត (Life Insurance)
២-សន្សំលុយសំរាប់ចូលនិវត្តន៍ (Retirement Planning)
៣-សន្សំលុយសម្រាប់កូនចូលរៀនមហាវិទ្យាល័យ (College Saving)
៤-រៀបចំទ្រព្យសម្បត្តិទុកឱ្យកូនចៅ (Estate Planning)


WUTHA CHIN MBA
Agent New York Life

ខ្ញុំអាចជួយពន្យល់ដល់បងប្អូនដោយមិនយកកម្រៃ
P. (610) 660 5897, Cell. P (267) 736 0445
wchin@ft.newyorklife.com



SATURDAY
6PM-MIDNIGHT
12.27.2008
រាត្រីរាំកំសាន្តក្នុងសប្តាហ៍
ក្រោយបុណ្យណូអែល
ថ្ងៃសៅរ៍ ទី២៧ ខែធ្នូ ពេលម៉ោង ៦យប់
មនោរម្យតន្ត្រី
MONOROM BAND
ដារីយ៉ា-Dariya
Lor, Bopha
Suos, Sappda
SAIGON MAXIM RESTAURANT
612-632 WASHINGTON AVE.
PHILADELPHIA, PA 19147
TEL: 215-271-8839
CHRISTMAS'S WEEK DANCE PARTY
PROPER ATTIRED
$20 PER PERSON
More Info: Danny at 267-784-9839
Email: danny.duk@gmail.com
www.MySpace.com/dukd
Poster: Siphann Touch 978-902-6693
E-mail: TouchDID@msn.com - This poster has been posted for FREE @ www.KhmerXpress.com
SATURDAY, DECEMBER 27, 2008 - 6PM-MIDNIGHT
ខ្ទួសាល " ជួបតំរូវជំពាក់ស្នេហ៍ " និងបើកកំដរអារម្មណ៍របស់លោកអ្នក រាល់រាត្រីថ្ងៃសុក្រ សៅរ៍ អាទិត្យ
ចាប់ពីម៉ោង ៧ : 00 ដល់ម៉ោង ១២ : 00 អាធ្រាត នៅ 612 WASHINTON AVE.
ដោយមានចម្រៀងខារ៉ាអូខេ បំរើភេសជ្ជៈ និងមានម្ហូបអាហារឆ្ងាញ់ពិសាជូនផង ។




2009 NEW YEAR'S EVE DANCE PARTY
WEDNESDAY
12-31-2008
6PM-1AM
COMPLIMENTARY CHAMPAGNE AT THE COUNTDOWN!
រាត្រីរាំកំសាន្តមុនថ្ងៃចូលឆ្នាំថ្មី ២០០៩
SAIGON MAXIM RESTAURANT
612-632 WASHINGTON AVE.
PHILADELPHIA, PA 19147
TEL: 215-271-8839
មនោរម្យតន្ត្រី
MONOROM BAND
WED.12.31.2008
នៅថ្ងៃពុធ ទី៣១ ខែធ្នូ ពេលម៉ោង ៦យប់ ដល់ម៉ោង ១ភ្លឺ
$20 PER PERSON
PROPER ATTIRED
MORE INFO: Danny at 267-784-9839
EMAIL: danny.duk@gmail.com
www.MySpace.com/dukd
Poster: Siphann Touch, 978-902-6693
E-mail: TouchDID@msn.com - This poster has been posted for FREE @ www.KhmerXpress.com
WEDNESDAY, DECEMBER 31, 2008 - 6PM-1AM
សូមរង់ចាំរាំកំសាន្ត នៅថ្ងៃទី១០ មករា ២០០៩ និង ទី១៤ កុម្ភៈ ២០០៩
ថ្ងៃ VALENTINE ជាមួយក្រុមតន្ត្រីដ៏ល្អើមតែមួយ នៅហ្វីឡាដែលហ្វៀ
គឺ " មនោរម្យតន្ត្រី " ចូលរួមច្រៀងដោយអ្នកចម្រៀងមកពីស្រុកខ្មែរថែមទៀតផង ។
" មនោរម្យតន្ត្រី " អាចលេងកំដរពិធីការ បុណ្យកំណើត ឬពិធីផ្សេងៗ តាមសំណើរបាន
សូមហៅរក ស៊ីន ទូច : (267) 970 0411